# តើដំណឹងល្អ
# គឺជាអ្វី?

*Bryan Chapell*

**What Is the Gospel? by Bryan Chapell**
តើដំណឹងល្អជាអ្វី? ដោយលោកគ្រូ៖ **Bryan Chapell**

**Copyright © 2011 by The Gospel Coalition**
បោះពុម្ពជាភាសាខ្មែររក្សាសិទ្ធិ © ២០២០ ដោយសកម្មភាពអន្តរជាតិ–កម្ពុជា

រក្សាសិទ្ធិគ្រប់បែបយ៉ាង។ យើងមិនអនុញ្ញាតឲ្យសៀវភៅនេះមានការបោះពុម្ពផ្សាយឡើងវិញ, ថតទុកក្នុងប្រព័ន្ធម៉ាស៊ីនកុំព្យូទ័រ, ឬចែកចាយបន្តរួមបញ្ចូលទាំង ការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក, បច្ចេកទេសថតចម្លង, ការថតទុកជាឯកសារសំឡេង។ល។ ដោយគ្មានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិដើមដែលនៅប្រទេសអាមេរិកឡើយ។

រចនាគម្របសៀវភៅភាសាអង់គ្លេស៖ Matthew Wahl

យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ រក្សាសិទ្ធិ©ឆ្នាំ១៩៥៤ ដោយសមាគមព្រះគម្ពីរសកល ព្រះគម្ពីរសញ្ញាថ្មី កែសម្រួល រក្សាសិទ្ធិ©ឆ្នាំ២០១៤, ២០១៦ (គកស) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន រក្សាសិទ្ធិ©ឆ្នាំ២០០៥ (គខប) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ រក្សាសិទ្ធិ©ឆ្នាំ២០១៤ (គគខ) ដោយព័ន្ធកិច្ចព្រះបន្ទូលនៃជីវិត, ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូលយើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្តេចសង្ឃរាជ ជួន ណាត។

រាល់ការសង្កត់សំណេរលើបទគម្ពីរទាំងអស់គឺត្រូវបានបន្ថែមឡើងដោយអ្នកនិពន្ធ

បកប្រែដោយ៖ លោកគ្រូ ឈាង បូរ៉ា ដោយមានការអនុញ្ញាតពីក្រុម The Gospel Coalition

ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ លោកគ្រូ វែល ណាថាន, លោក ទេព រ៉ូ, លោក ប៊ុន ដេត និងលោក ខែម បូឡុង

សូមថ្លែងអំណរគុណចំពោះ៖ លោក រ៉ង វីរាម, លោកស្រី ថាវ ប៊ុនរី, លោក ប៉ក់ ស៊ាវយី, កញ្ញា រ៉ង ស្រីណុង, កញ្ញា ហួត ណារ, កញ្ញា សាវ ឡី, លោក ប៉ក់ សុថេប, លោកស្រី ពូល រដ្ឋា និង លោក ប៊ុនណើ ធារិទ្ធ

បោះពុម្ពលើកទី១ ចំនួន ១.០០០ ក្បាល ២០២០ នៃគ.ស. នៅព្រះរាជាណាចក្រកម្ពុជា
For ordering information please visit:
ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ៖
https://www.cambodianchristianresources.com/books/gospel-coalition-booklets/

# មាតិកា

អ្វីដែលព្រះជាម្ចាស់ទាមទារ ទ្រង់ប្រទាន . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៨

អ្វីដែលព្រះជាម្ចាស់ប្រទានឲ្យ ទ្រង់ធ្វើឲ្យល្អឥតខ្ចោះ. . . . . . . . . . . . . . . . . . . . . . . . . ២៧

អស់អ្នកដែលព្រះជាម្ចាស់ធ្វើឲ្យល្អឥតខ្ចោះ ទ្រង់ប្រើប្រាស់ . . . . . . . . . . . . . . . . . . . .៥០

*«ព្រះគ្រីស្ទយេស៊ូវទ្រង់បានយាងមកក្នុងលោកីយ៍*
*ដើម្បីនឹងជួយសង្គ្រោះមនុស្សមានបាប»*
*១ធីម៉ូថេ ១:១៥*

ព្រឹត្តិការណ៍នានាដែលបាននាំឲ្យគេមកចាប់គាត់បានចាប់ផ្ដើមជាច្រើនឆ្នាំមកហើយ។ កាលគាត់កំពុងតែធំពេញវ័យឡើង ប្រយោគសមរម្យមួយដែលគ្រួសារយើងប្រើប្រាស់ ដើម្បីពណ៌អំពីសមត្ថភាពនៃការគិតគូររបស់ប្អូនប្រុសខ្ញុំគឺ «គាត់មានការពិបាកខ្លាំងណាស់ក្នុងការរៀនបើប្រៀបធៀបជាមួយនឹងអ្នកទៃ»។ ខណៈពេលដែលខួរក្បាលគាត់មិនបានលូតលាស់ រូបកាយ និងឆន្ទៈរបស់ ដាវីឌ បានលូតលាស់យ៉ាងខ្លាំងស្របពេលដែលឪពុកម្ដាយរបស់ខ្ញុំកាន់តែចាស់ទៅៗ។ ភាពស្មុគស្មាញនៃការមើលខុសត្រូវគាត់ ក៏ដូចជាបញ្ហាផ្ទាល់ខ្លួនរបស់ឪពុកម្ដាយខ្ញុំផ្ទាល់ បានបណ្ដាលឲ្យពួកគាត់លែងលះគ្នា ហើយក៏កាន់តែបណ្ដាលឲ្យប្អូនប្រុសខ្ញុំមានបន្ទុកថែមទៀត។ ក្នុងនាមជាក្មេងជំទង់ម្នាក់ ដាវីឌ ប្រាថ្នាចង់ឯករាជ្យ ហើយការមិនលូតលាស់ផ្នែកសមត្ថភាពខាងឯការគិតគូររបស់គាត់គឺជាបញ្ហាមួយដែលយើងបារម្ភ។ ទាក់ទងនឹងមិត្តភក្តិ និងការរំភើបចិត្ត គាត់តែងតែបង្កើតទំនាក់ទំនងដែលនាំឲ្យមានបញ្ហា។ ចំណុចដែលគួរនឹងកើតឡើងក៏បានក្លាយទៅជាលទ្ធផល។

ការដែលប៉ូលិសមកចាប់គាត់ដាក់គុកគឺវាលើសធ្ងន់ធ្ងរខ្លាំងជាងការដែលខួរក្បាលរបស់គាត់អាចទទួលបានទៅទៀត។ ចំណុចដែលគាត់គ្រាន់តែដឹងនោះគឺភាពភ័យខ្លាចដ៏មហិមាដែលបុគ្គលម្នាក់មាន ក្នុងនាមជាក្មេងម្នាក់ដែលមានបញ្ហាខួរក្បាលដែលនឹងត្រូវដកបទពិសោធន៍ក្នុងគុក។ គាត់បានឱបដៃ

ឱបជើងពួននៅឯកន្លៀតបន្ទប់ ហើយញ័ររន្ធត់។

ភាពភ័យខ្លាចរបស់ប្អូនប្រុសខ្ញុំ ដែលគេអាចមើលឃើញបានយ៉ាងជាក់ស្ដែង បានបញ្ឆេះឡើងនូវអ្វីមួយនៅក្នុងចិត្តរបស់បុរសម្នាក់ទៀតនៅក្នុងបន្ទប់ជាមួយគាត់ដែរ។ ហើយទោះបើខ្លួនគាត់មានការលំបាកយ៉ាងណាក៏ដោយ ក៏គាត់បានចែកចាយជាមួយ ដាវីឌ នូវសារនៃសេចក្ដីមេត្តាករុណារបស់ព្រះជាម្ចាស់ថា៖ «ព្រះយេស៊ូវអាចជួយឯងបាន។ ចូរទុកចិត្តលើទ្រង់ចុះ។»

សេចក្ដីពិតដែល ដាវីឌ បានរៀននៅសាលាថ្នាក់ថ្ងៃអាទិត្យសម្រាប់មនុស្សដែលមានបញ្ហាផ្នែកកាយសម្បទា និងផ្លូវចិត្តដែល ដាវីឌ ធ្លាប់បានចូលរួមកាលពីគាត់នៅជាកុមារ ក៏ត្រូវបានរម្លឹកសារឡើងវិញចំពោះគាត់។ គាត់បានអធិស្ឋានទៅព្រះជាម្ចាស់ទូលសូមឲ្យអត់ទោសបាបគាត់ ហើយគាត់ក៏បានជឿទុកចិត្តលើព្រះគ្រីស្ទជាព្រះសង្គ្រោះរបស់គាត់។

ដាវីឌ នឹងត្រូវជាប់គុកជាច្រើនឆ្នាំទៀត។ ហើយគាត់ក៏នៅជាប់ជាមួយព្រះគ្រីស្ទយ៉ាងអស់កល្បជានិច្ចដែរ—គាត់បានទទួលការអត់ទោស ទទួលបានការស្ដារឡើងវិញ រាប់ថានេះជាមនុស្សម្នាក់ដែលមានតម្លៃ និងទទួលបានការបំផ្លាស់បំប្រែ។ នេះហើយគឺជាដំណឹងល្អសម្រាប់ប្អូនប្រុសខ្ញុំ និងសម្រាប់អស់អ្នកណាដែលទទួលជឿទុកចិត្តលើព្រះយេស៊ូវ។

ព្រះគម្ពីរប្រើប្រាស់ពាក្យ «ដំណឹងល្អ» ដើម្បីសំដៅទៅលើព្រះរាជសារថា ព្រះជាម្ចាស់បានបំពេញសេចក្ដីសន្យារបស់ទ្រង់ក្នុងការចាត់ព្រះសង្គ្រោះឲ្យយាងមករំដោះអស់អ្នកដែលបែកបាក់ ស្ដារឡើងវិញនូវសិរីល្អនៃអ្វីដែលទ្រង់បានបង្កើត ហើយនិងសោយរាជ្យលើគ្រប់អ្វីៗទាំងអស់ដោយសេចក្ដី

មេត្តាករុណា និងភាពយុត្តិធម៌។ នេះឯងជាមូលហេតុដែលថា ការសង្ខេបដ៏ល្អលើដំណឹងល្អគឺ «ព្រះគ្រីស្ទយេស៊ូវទ្រង់បានយាងមកក្នុងលោកីយ៍ ដើម្បីនឹងជួយសង្គ្រោះមនុស្សមានបាប» (១ធីម៉ូថេ ១:១៥)។

ការរំដោះ ការស្តារឡើងវិញ និងការសោយរាជ្យរបស់ព្រះជាម្ចាស់គឺទាក់ទងគ្នានៅស្ថានភាពខាងឯព្រលឹងវិញ្ញាណរបស់យើង ប៉ុន្តែមិនមែនមានត្រឹមតែព្រំដែននឹងធាតុពិតនៃព្រលឹងវិញ្ញាណប៉ុណ្ណោះនោះទេ។ តាមរយៈព្រះយេស៊ូវគ្រីស្ទ ព្រះជាម្ចាស់នៃយើងបានរំដោះរាស្ត្ររបស់ទ្រង់ចេញពីផលកម្មដ៏នៅអស់កល្បជានិច្ចនៃអំពើបាបរបស់មនុស្សលោកដែលបានរាលដាលលើគ្រប់អ្វីៗទាំងអស់។ ការសង្គ្រោះរបស់យើងមានរួមបញ្ចូលទាំងយើង ប៉ុន្តែវាក៏ធំជាងយើងផងដែរ។

មុននឹងយើងបន្តស្វែងយល់ថែមទៀតអំពីសេចក្តីពិតដ៏អស្ចារ្យទាំងអស់នេះ យើងក៏ត្រូវតែទទួលស្គាល់ផងដែរថា ព្រះគម្ពីរមិនមែនគ្រាន់តែបានលើកឡើងនូវចំណុចនេះ ដើម្បីធ្វើឲ្យយើងរំភើបចិត្តប៉ុណ្ណោះឡើយ។ ព្រះជាម្ចាស់បានបើកសម្តែងសេចក្តីពិតទាំងនោះ ដើម្បីឲ្យមនុស្សមានបាបដូច ដាវីឌ និងលោកអ្នក និងខ្ញុំអាចមានសេរីភាពដ៏នៅអស់កល្បជានិច្ចចេញពីពិរុទ្ធភាព និងអំណាចនៃអំពើបាបតាមរយៈការជឿទុកចិត្តលើដំណឹងល្អដែលថាព្រះយេស៊ូវគឺជាព្រះអម្ចាស់ដែលយាងមក ដើម្បីនឹងសង្គ្រោះយើង។ ខាងក្រោមនេះគឺជាចំណុចគន្លឹះមួយចំនួនស្តីអំពីដំណឹងល្អ។

## អ្វីដែលព្រះជាម្ចាស់ទាមទារ ទ្រង់ប្រទាន

យើងទំនងជាមិនពេញចិត្តនឹងគំនិតនៅពេលដែលបុគ្គលណាម្នាក់ចាត់ទុកយើងថាជា «មនុស្សមានបាប» ឡើយ ជាពិសេសបើយើងប្រើប្រាស់ពាក្យនេះសំដៅទៅលើតែអស់អ្នកណាដែលកាប់សម្លាប់គេ និងអស់អ្នកដែលរំលោភបំពានលើរាងកាយកុមារ។ ប៉ុន្តែ ព្រះគម្ពីរបានចែងថា ព្រះជាម្ចាស់បរិសុទ្ធយ៉ាងពេញទី ហើយថាអស់អ្នកណាដែលមិនគ្រាប់តាមស្មើគ្នានឹងភាពល្អឥតខ្ចោះរបស់ទ្រង់ គឺសុទ្ធតែជា «មនុស្សមានបាប» ដែលឃ្លានេះមានន័យដ៏សាមញ្ញថាជាការមិនគ្រាប់តាមស្តង់ដាររបស់ព្រះជាម្ចាស់។ ទោះបើយើងប្រព្រឹត្តអំពើបាប មិនថាដល់កម្រិតណាក៏ដោយ ក៏យើងបានក្លាយទៅជាអ្វីមួយផ្សេងទៀតដែលមិនស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់រួចបាត់ទៅហើយ (រ៉ូម ៣:២៣; យ៉ាកុប ២:១០)។ ព្រះអង្គបានបង្កើតយើងមក ដើម្បីឲ្យយើងឆ្លុះបញ្ចាំងអំពីលក្ខណៈនៃភាពបរិសុទ្ធរបស់ទ្រង់ (១ពេត្រុស ១:១៦)។ ដូច្នេះហើយ កំហុសខុសឆ្គងរបស់យើងមិនគ្រាន់តែធ្វើឲ្យយើងឈឺចាប់ប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងបង្ខូចទំនាក់ទំនងរបស់យើងជាមួយនឹងព្រះជាម្ចាស់ទៀតផង (អេភេសូរ ៤:៣០)។

### *រូបអង្គព្រះជាម្ចាស់*

បញ្ហានៃទំនាក់ទំនងរបស់យើងជាមួយនឹងព្រះជាម្ចាស់បានចាប់ផ្តើមនៅពេលដែលឪពុកម្តាយដំបូងរបស់យើងបានប្រព្រឹត្តអំពើបាប ដែលការនោះបានបណ្តាលឲ្យយើងមាននិស្ស័យពុករលួយ (រ៉ូម ៥:១២)។ ចាប់តាំងពីជំនាន់លោក អ័ដាម និងនាង អេវ៉ា មកដល់សព្វថ្ងៃនេះ បុគ្គលគ្រប់ៗរូបយល់ពីភាពឈឺចាប់នៅពេលដែលយើងធ្លាប់បរាជ័យចំពោះអស់អ្នកដែលយើងស្រឡាញ់

ធ្វើឲ្យអ្នកដទៃឈឺចាប់នឹងបោះបង់ទស្សនៈរបស់ខ្លួនចោល។ យើងទាំងអស់គ្នាសុទ្ធតែធ្លាប់ស្គាល់អំពីភាពអាម៉ាស់ និងវិប្បដិសារី។ តាមពិតទៅចំណុចនេះឆ្លុះបញ្ចាំងអំពីធាតុពិតខាងឯវិញ្ញាណមួយ ដែលយើងទំនងជាមិនទាន់ទទួលស្គាល់នៅឡើយ៖ យើងមានពិរុទ្ធភាព ពីព្រោះព្រះជាម្ចាស់បានបង្កើតយើងមកឲ្យមានលក្ខណៈដូចជាព្រះអង្គ ប៉ុន្តែយើងបានបរាជ័យក្នុងការរស់នៅដោយបង្ហាញពីលក្ខណៈនោះ (រ៉ូម ៣:១០)។

ព្រះជាម្ចាស់បានបង្កើតយើងមកដូចរូបអង្គទ្រង់ (លោកុប្បត្តិ ១:២៦-២៧)។ ព្រះជាម្ចាស់បានសូនយើងមកឲ្យដូចជាអង្គទ្រង់ ដើម្បីឲ្យយើងអាចនឹងស្រឡាញ់ទ្រង់ និងអ្នកដទៃដែលព្រះអង្គបានបង្កើតដូចរូបអង្គទ្រង់ផងដែរ។ នៅពេលដែលយើងប្រព្រឹត្តអំពើបាប នោះមានន័យថា យើងកំពុងតែទាស់ប្រឆាំងនឹងលក្ខណៈដើមរបស់យើង ហើយមានអ្វីមួយនៅក្នុងជម្រៅចិត្តយើងបានធ្វើឲ្យយើងមានអារម្មណ៍មិនស្រួល។ អារម្មណ៍នៃពិរុទ្ធភាពដែលយើងមានគឺជាសំឡេងបន្ទរនៃភាពឈឺចាប់ដែលចិត្តរបស់យើងមាន—នៅពេលណាដែលយើងប្រព្រឹត្តអំពើបាប—ព្រោះការនោះបានដាក់គម្លាតរវាងយើងក្នុងទំនាក់ទំនងរបស់យើង ដែលព្រះជាម្ចាស់បានសូនយើងមក ដើម្បីឲ្យយើងមានទំនាក់ទំនងល្អជាមួយនឹងព្រះអង្គ។

ដើម្បីឲ្យយើងមានទំនាក់ទំនងដ៏ស្និតស្នាលជាមួយនឹងព្រះជាម្ចាស់បានទ្រង់បានតម្រូវឲ្យយើងមានភាពបរិសុទ្ធ ប៉ុន្តែទាំងលក្ខណៈ និងទង្វើរបស់យើងបានដាក់គម្លាតយើងចេញពីព្រះជាម្ចាស់។ តើយើងអាចដោះស្រាយបញ្ហានេះបានដោយរបៀបណាទៅ? យើងមិនអាចដោះស្រាយបានទេ។ យើងជា

មនុស្សមិនល្អឥតខ្ចោះ ហើយក៏មិនអាចធ្វើឲ្យខ្លួនឯងបរិសុទ្ធលើសជាងដៃដែលបានប្រឡាក់ភក់អាចទៅជូតអាវឃើតពណ៌សឲ្យបានស្អាតបានឡើងវិញដែរ។

មានតែព្រះជាម្ចាស់មួយអង្គគត់ដែលអាចដោះស្រាយទំនាក់ទំនងរបស់យើងជាមួយនឹងទ្រង់បាន ហើយព្រះអង្គធ្វើការទាំងនោះដោយប្រទានឲ្យមាននូវភាពបរិសុទ្ធដែលទ្រង់ទាមទារ។ ព្រះជាម្ចាស់គឺជាអង្គដែលចាប់ផ្ដើម (១យ៉ូហាន ៤:១៩)។ តាមរយៈព្រះយេស៊ូវ ព្រះជាម្ចាស់នៃយើងបានរំដោះយើងចេញពីផលកម្មនៃអំពើបាបរបស់យើង។ ព្រះអង្គប្រទានឲ្យនូវអ្វីដែលយើងមិនអាចមាន ហេតុដូច្នេះហើយបានជាពេលយើងហៅការប្រទានឲ្យរបស់ទ្រង់មួយនេះថា «ដំណឹងល្អនៃព្រះគុណ»។ ពាក្យ «ព្រះគុណ» មានន័យថា «អំណោយទាន»—ជាអ្វីមួយដែលព្រះអង្គប្រទានទៅកាន់នរណាម្នាក់ដែលមិនអាចមាននូវអ្វីដែលពួកគាត់ត្រូវការបាន—ប្រៀបប្រដូចជានរណាម្នាក់ឲ្យអាវឃើតថ្មីមួយទៅកាន់បុគ្គលណាម្នាក់ដែលបានធ្វើឲ្យអាវរបស់ខ្លួនប្រឡាក់ទៅដោយភក់ដែរ។

## *ភាពបរិសុទ្ធរបស់ព្រះជាម្ចាស់*

ព្រះនាមរបស់ព្រះយេស៊ូវគ្រីស្ទរៀបរាប់យ៉ាងក្បោះក្បាយអំពីរបៀបដែលទ្រង់ធ្វើឲ្យយើងបានបរិសុទ្ធ។ ព្រះនាមរបស់ព្រះយេស៊ូវមានន័យថា «អ្នករំដោះ»។ បេសកកម្មរបស់ព្រះអង្គគឺធ្វើជាអ្នករំដោះ (ឬក៏សង្គ្រោះ) យើងចេញពីកម្មផលនៃអំពើបាបរបស់យើង។ ពាក្យបន្ថែម «គ្រីស្ទ» គឺជាការពណ៌នាអំពើគោលបំណងរបស់ព្រះយេស៊ូវ ជាជាងផ្ដោតទៅលើព្រះនាមរបស់ទ្រង់ផ្ទាល់។ ពាក្យ «គ្រីស្ទ» គឺជានាមនៃឋានៈដែលមានន័យថា «អ្នកដែលព្រះជាម្ចាស់បានជ្រើស

តាំង»។ ព្រះវរបិតាបានជ្រើសតាំងព្រះយេស៊ូវឲ្យធ្វើជាអ្នកតំណាងទ្រង់ក្នុងការប្រទានភាពបរិសុទ្ធរបស់ព្រះអង្គដល់មនុស្សលោក។ អស់រយៈពេលជាច្រើនសតវត្ស ព្រះជាម្ចាស់បានសន្យាតាមរយៈពួកហោរារបស់ព្រះអង្គថា ទ្រង់នឹងចាត់អ្នកដែលទ្រង់បានជ្រើសតាំងឲ្យមកសង្គ្រោះរាស្ត្ររបស់ទ្រង់ (កិច្ចការ ៣:១៨-២០)។ ទោះជាយ៉ាងណាក្តីក៏មនុស្សជាច្រើននាក់មានការភ្ញាក់ផ្អើលពេលដែលពួកគាត់ឃើញថា អង្គដែលព្រះជាម្ចាស់បានជ្រើសតាំងគឺជាព្រះរាជបុត្រាផ្ទាល់របស់ទ្រង់។

ព្រះយេស៊ូវបានយាងមកក្នុងនាមជាអ្នកតំណាងដ៏ល្អឥតខ្ចោះនៃរូបអង្គព្រះជាម្ចាស់។ ទោះបើព្រះអង្គជាព្រះក៏ដោយ ក៏ព្រះយេស៊ូវបានយកសណ្ឋានជាមនុស្ស (កាឡាទី ៤:៤-៥; ភីលីព ២:៦-១១)។ ទ្រង់គឺជាព្រះដែលបានយាងមកយកកំណើត (ពាក្យ «យកកំណើត» មានន័យថា «ក្នុងសាច់ឈាម»)។ ព្រះយេស៊ូវមានលក្ខណៈដូចយើងក្នុងរាល់គ្រប់ចំណុចលើកលែងតែមួយ៖ ព្រះអង្គគ្មានអំពើបាបសោះ (ហេព្រើរ ៤:១៥)។ ព្រះយេស៊ូវមិនមែនគ្រាន់តែមិនបានប្រព្រឹត្តអំពើរំលងប៉ុណ្ណោះទេ ប៉ុន្តែដោយសារព្រះអង្គត្រូវបានព្រះវិញ្ញាណបរិសុទ្ធចាប់បដិសន្ធិក្នុងរបៀបដ៏អស្ចារ្យលើនាង ម៉ារា ដែលជាក្រមុំព្រហ្មចារី ដែលការនោះមានន័យថា ទ្រង់មិនមានការចាប់កំណើតក្នុងភាពពុករលួយ ដូចដែលមនុស្សគ្រប់ៗរូបមាននោះទេ (ម៉ាថាយ ២:២០-២៣)។

ភាពបរិសុទ្ធរបស់ព្រះគ្រីស្ទនាំមកនូវពីរចំណុចសម្រាប់យើង៖ ទីមួយ វាបានបង្ហាញយើងអំពីរបៀបដែលយើងត្រូវរស់នៅសម្រាប់ព្រះជាម្ចាស់។ ប្រសិនបើមនុស្សម្នាក់មានជីវិតដែលពេញទៅដោយសេចក្តីស្រឡាញ់ និងគ្មានភាព

អាត្មានិយម នោះវានឹងមានលក្ខណៈដូចជាព្រះជន្មរបស់ព្រះយេស៊ូវជាមិនខាន (១យ៉ូហាន ៣:១៦)។ តាមរយៈព្រះអង្គ យើងបានរៀនអំពីរបៀបនៃការរស់នៅឲ្យបានពេញទី ពោលគឺឲ្យយើងរស់នៅតាមរបៀបដែលព្រះជាម្ចាស់សព្វព្រះហឫទ័យនៅពេលដែលទ្រង់បានបង្កើតយើងមក—គឺមានលក្ខណៈជាមនុស្សទាំងស្រុង ហើយស្របពេលជាមួយគ្នានោះដែរក៏មានការប្រកបគ្នាយ៉ាងល្អឥតខ្ចោះជាមួយនឹងព្រះជាម្ចាស់ថែមទៀត។ ចុះបើយើងមិនអាចរស់នៅយ៉ាងពេញលេញបាន ហើយល្អឥតខ្ចោះក្នុងការប្រកបគ្នាជាមួយនឹងព្រះជាម្ចាស់ដូចជាព្រះយេស៊ូវ? តើនឹងមានរឿងអ្វីកើតឡើងទៅ? នោះមានន័យថាយើងត្រូវការការប្រទានឲ្យទីពីរនៃភាពបរិសុទ្ធរបស់ព្រះយេស៊ូវ។ ការប្រទានឲ្យទីពីរនេះ គឺលើសពីការបង្ហាញយើងអំពីរបៀបដែលយើងរស់នៅសម្រាប់ព្រះជាម្ចាស់ ប៉ុន្តែ វាបណ្តាលឲ្យយើងអាចរស់នៅជាមួយនឹងព្រះជាម្ចាស់តាមរយៈការស្ កប់ចិត្តដោយស្តាប់បង្គាប់តាមស្តង់ដាររបស់ព្រះអង្គវិញ។

## *សេចក្តីយុត្តិធម៌របស់ព្រះជាម្ចាស់*

ព្រះយេស៊ូវអាចធ្វើជាយញ្ញបូជាយ៉ាងល្អឥតខ្ចោះជំនួសយើងបានដោយសារភាពបរិសុទ្ធរបស់ទ្រង់។ ចំពោះអ្នកស្តាប់សម័យនេះ ការលើកឡើងបែបនោះគឺហាក់បីដូចជាប្លែកណាស់ ប៉ុន្តែនោះជារាជសារដែលព្រះគម្ពីរបានរៀបរាប់តាំងពីដើមដល់ចប់។ អំពើបាបរបស់យើងមិនមែនគ្រាន់តែជាអ្វីដែលធ្វើឲ្យព្រះជាម្ចាស់មានការមួម៉ៅប៉ុណ្ណោះឡើយ។ អំពើបាបនៃមនុស្សលោកយើងបាននាំឲ្យមានការរងទុក្ខដែលមិនអាចប៉ាន់ស្មាននឹកឃើញដល់។ ព្រះជាម្ចាស់មិនមើលរំលងកំហឹងដែលយើងបញ្ចេញ ការឈ្លានពានដែលយើងបង្ក ការរង

ទុក្ខដែលយើងមិនអើពើ ឬក៏ភាពអយុត្តិធម៌ដែលយើងមិនរវីរវល់នោះឡើយ។ ព្រះដ៏បរិសុទ្ធមិនអាចគ្រាន់តែបិទភ្នែក ឬក៏បិទព្រះកាណ៌ចំពោះអំពើបាបបែបនោះទេ។ ជនរងគ្រោះស្រែករកភាពយុត្តិធម៌ ហើយសេចក្តីមេត្តាករុណារបស់ព្រះជាម្ចាស់ក៏បានប្រទាននូវអ្វីដែលសេចក្តីសុចរិតរបស់ទ្រង់តម្រូវឲ្យមានតាមរយៈយញ្ញបូជារបស់ព្រះយេស៊ូវ។

ដោយសារព្រះរាជបុត្រារបស់ព្រះជាម្ចាស់មិនមានអំពើបាប ការស្ម័គ្រព្រះទ័យរបស់ព្រះអង្គក្នុងការរងទុក្ខលើឈើឆ្កាង នឹងការទទួលយកទារុណកម្មដែលយើងស័ក្តិសមនឹងទទួល គឺមានលក្ខណៈលើសជាងការដែលមនុស្សយើងអាចតបស្នងក្នុងការថ្វាយទៅកាន់ទ្រង់វិញថែមទៀត។ សេចក្តីសុចរិតរបស់ព្រះគ្រីស្ទគឺធំខ្លាំងជាងសេចក្តីមិនសុចរិតរបស់យើង ដែលយញ្ញបូជារបស់ទ្រង់គឺល្មមគ្រប់គ្រាន់ក្នុងការបង់ថ្លៃសម្រាប់អំពើបាបនៃពិភពលោកទាំងមូល និងសម្រាប់រាល់ពេលវេលា។ (រ៉ូម ៥:១៥-១៩; ហេព្រើរ ៩:២៦-២៨; ១ពេត្រុស ៣:១៨; ១យ៉ូហាន ២:២)។ ព្រះជាម្ចាស់បានទទួលយកយញ្ញបូជារបស់ព្រះយេស៊ូវជំនួសការដាក់ទារុណកម្មលើយើង (១ពេត្រុស ២:២៤)។ ព្រះយេស៊ូវបានបង់ថ្លៃបំណុលដែលយើងជំពាក់សេចក្តីយុត្តិធម៌របស់ព្រះជាម្ចាស់ ដែលយើងមិនអាចបង់ថ្លៃបាន (ទំនុកតម្កើង ៤៧:៧-៩; ទីតុស ២:១១-១៤)។ ការរងទុក្ខរបស់ព្រះអង្គលោះបាបសម្រាប់ (ឬក៏ «គ្របបាំង») អំពើរំលងដែលយើងប្រព្រឹត្ត (១យ៉ូហាន ៤:១០)។ ការសុគតរបស់ព្រះអង្គបានរំដោះយើងចេញពីស្ថាននរកដែលយើងស័ក្តិសមនឹងទទួល (កាឡាទី ៣:១៣-១៤)។

ចំពោះអស់អ្នកដែលនៅក្នុងចំណោមយើង ដែលតយុទ្ធក្នុងការមានអារម្មណ៍

ពិរុទ្ធភាព ការផ្តត់ផ្គង់របស់ព្រះគ្រីស្ទគឺជាដំណឹងដ៏ល្អក្រៃលែង។ នៅក្នុងគុក ដាវីឌ ដែលជាប្អូនរបស់ខ្ញុំ មិនអាចបង់ថ្លៃលោះបំណុលសម្រាប់អំពើឧក្រិដ្ឋ ដែលគាត់បានប្រព្រឹត្តនោះទេ ដូចដែលយើងជាមនុស្សមានពេញទៅដោយ ពិរុទ្ធភាពនៃអំពើបាបក៏មិនអាចនឹងបង់ថ្លៃលោះបំណុលដែលយើងជំពាក់ព្រះ ដ៏បរិសុទ្ធដោយសារយើងបានប្រព្រឹត្តល្មើសទាស់នឹងក្រឹត្យវិន័យរបស់ទ្រង់ បានផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារព្រះយេស៊ូវបានយាងមក ដើម្បីបង់ថ្លៃលោះបំណុលខាងឯព្រលឹងវិញ្ញាណរបស់យើង ទោះបើយើងជា មនុស្សទុគ៌តខាងឯព្រលឹងវិញ្ញាណក៏ដោយ ក៏ទាំង ដាវីឌ រួមទាំងលោកអ្នក ហើយនិងខ្ញុំក៏អាចរស់នៅដោយមានចិត្តដែលទទួលបាននូវសេរីភាពចេញ ពីភាពអាម៉ាស់បានដែរ។

## *សេចក្តីសុចរិតរបស់ព្រះគ្រីស្ទ*

យញ្ញបូជារបស់ព្រះគ្រីស្ទធ្វើឲ្យភាពយុត្តិធម៌របស់ព្រះជាម្ចាស់មានការស្កប់ព្រះ ហឫទ័យ (រ៉ូម ៥:២០-២១)។ នេះមានន័យថា និមិត្តសញ្ញាឋានៈរបស់ខ្ញុំខាងឯ ព្រលឹងវិញ្ញាណបានក្លាយទៅជាលក្ខណៈមួយហាក់បីដូចជាខ្ញុំមិនដែលប្រព្រឹត្ត អំពើបាបទាល់តែសោះ (អេសាយ ១:១៨)។ ពួកទេវវិទូហៅការប្រកាសមួយ នេះរបស់ព្រះជាម្ចាស់ដែលទាក់ទងទៅនឹងឋានៈបរិសុទ្ធថ្មីដែលយើងទទួល ថា «ការរាប់ជាសុចរិត»។ ការរាប់ជាសុចរិតកើតឡើងចេញពីការប្តូរដ៏អស្ចារ្យ មួយដែលបានកើតឡើងនៅលើឈើឆ្កាងរបស់ព្រះគ្រីស្ទ។ ព្រះអង្គបានយក នូវអំពើបាបរបស់យើងមកដាក់លើរូបអង្គទ្រង់ផ្ទាល់ ហើយជាលទ្ធផលព្រះ អង្គក៏បានប្រទានមកកាន់យើងនូវសេចក្តីសុចរិតរបស់ទ្រង់ដែរ (២កូរិនថូស

៥:២១ ; ១ពេត្រុស ៣:១៨)។ ទ្រង់បានក្លាយដូចជាយើង (មានអំពើបាប) ដើម្បីឲ្យយើងអាចក្លាយដូចជារូបអង្គទ្រង់វិញបាន (បរិសុទ្ធ)។

ការប្រទានឲ្យដ៏អស្ចារ្យរបស់ព្រះគ្រីស្ទសម្រាប់អំពើបាបបានអនុញ្ញាតឲ្យខ្ញុំបានទទួលស្គាល់ភាពធ្ងន់ធ្ងរនៃអំពើបាបរបស់ប្អូនប្រុសខ្ញុំ—និងរបស់ខ្ញុំ ព្រមទាំងរបស់លោកអ្នកដែរ។ មនុស្សគ្រប់ៗរូប—មិនថាពួកគាត់មានអំពើបាបធំក្រៃលែងប៉ុណ្ណាក៏ដោយនៅក្នុងជីវិតខ្លួន—ក៏គាត់អាចនឹងទទួលបានការលោះបាបតាមរយៈយញ្ញបូជារបស់ព្រះយេស៊ូវបានដែរ។

ភស្តុតាងមួយទាក់ទងនឹងដំណឹងដ៏ល្អមួយនេះគឺខគម្ពីរដែលនៅសល់ក្នុងខគម្ពីរដែលយើងបានលើកឡើងជាសម្រង់សម្ដីនៅក្នុងចំណុចផ្ដើមនៃកូនសៀវភៅមួយនេះ។ សាវ័ក ប៉ុល បានសរសេរថា «ព្រះគ្រីស្ទយេស៊ូវទ្រង់បានយាងមកក្នុងលោកីយ៍ដើម្បីនឹងជួយសង្គ្រោះមនុស្សមានបាប ដែលខ្ញុំនេះជាលេខ១ក្នុងពួកគេ» (១ធីម៉ូថេ ១:១៥)។ មុនសាវ័ក ប៉ុល ទទួលជឿ គាត់បានជេរប្រមាថព្រះយេស៊ូវ និងបានសម្លាប់អស់អ្នកដែលដើរតាមព្រះអង្គ។ ប៉ុន្តែឥឡូវនេះសាវ័ក ប៉ុល អាចបង្ហាញភាពរីករាយយ៉ាងក្រៃលែងដែលថា ការធួននឹងបាបរបស់ព្រះគ្រីស្ទបានទូទាត់យ៉ាងពេញទីសម្រាប់អំពើល្មើសទាំងអស់នោះ—មិនមែនដោយសារតែភាពតូចតាចនៃអំពើបាបរបស់សាវ័ក ប៉ុលនោះទេ ប៉ុន្តែដោយសារភាពធំសម្បើមរបស់ឈើឆ្កាងទៅវិញទេតើ។ យញ្ញបូជារបស់ព្រះយេស៊ូវគ្រីស្ទមានការគ្រប់គ្រាន់ក្នុងការធួននឹងបាបសម្រាប់អំពើបាបដ៏ធំបំផុត និងសម្រាប់អ្នកប្រព្រឹត្តអំពើបាបដ៏ខ្លាំងជាងគេបំផុតដែរ។

## សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់

ប៉ុន្តែ តើយើងអាចប្រាកដឲ្យច្បាស់បានដោយរបៀបណា ដែលយើងអាចដឹងយ៉ាងពិតប្រាកដថា យើងអាចនឹងទទួលបានសេចក្តីសង្គ្រោះពីព្រះគ្រីស្ទបាន? សូម្បីតែព្រះយេស៊ូវក៏បានមានព្រះបន្ទូលអំពីមនុស្សមួយចំនួនដែលកំពុងទៅស្ថាននរកដែរ (ម៉ាថាយ ២៣:៣៣; យ៉ូហាន ៣:១៨) ដូច្នេះ យើងដឹងថាការធួននឹងបាបរបស់ព្រះគ្រីស្ទ—ទោះបើថាវាគ្រប់គ្រាន់សម្រាប់មនុស្សគ្រប់ៗរូប—ក៏មិនមែនថា មនុស្សគ្រប់ៗរូបនឹងទទួលសេចក្តីសង្គ្រោះបានដែរ។ តើយើងមានការធានាអះអាងពីនរណាដែលថា យើងអាចនឹងទទួលបានការធួននឹងបាបមួយនេះទៅ? ចម្លើយគឺថា យើងត្រូវតែចងចាំថាព្រះជាម្ចាស់ផ្តត់ផ្តង់នូវអ្វីដែលយើងទាមទារ។

ព្រះជាម្ចាស់មិនទាមទារឲ្យយើងទិញការអភ័យទោសរបស់ទ្រង់ឡើយ ព្រះអង្គមិនបានបង្គាប់ឲ្យយើងទៅធ្វើកិច្ចការដ៏អស្ចារ្យណាមួយខាងឯព្រលឹងវិញ្ញាណ ឬក៏ឲ្យយើងពិតជាមានអារម្មណ៍វិប្បដិសារីដ៏ខ្លាំងក្លា ដើម្បីទូទាត់សម្រាប់អំពើបាបរបស់យើងផងដែរ។ ផ្ទុយពីនោះទៅវិញ ដំណឹងល្អគឺថាព្រះជាម្ចាស់ប្រទាននូវការអភ័យទោសរបស់ទ្រង់តាមរយៈព្រះគុណតែមួយគត់ (រ៉ូម ៣:២៣-២៤)។ ព្រះអង្គបានប្រទានសេចក្តីស្រឡាញ់របស់ទ្រង់មកកាន់យើង ជាជាងទាមទារឲ្យយើងទិញវា។

ប្រសិនបើយើងត្រូវធ្វើអ្វីមួយ ដើម្បីទិញសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ នោះយើងនឹងមានការពិបាកណាស់ក្នុងការស្តាប់បង្គាប់នូវបញ្ញត្តិចម្បងរបស់ទ្រង់ «ត្រូវឲ្យស្រឡាញ់ព្រះអម្ចាស់ ជាព្រះនៃឯងឲ្យអស់អំពីចិត្ត អស់អំពីព្រលឹង

ហើយអស់អំពីគំនិតឯង» (ម៉ាថាយ ២២:៣៧)។ ប្រសិនបើបុគ្គលណាម្នាក់នឹងគ្រាន់តែស្រឡាញ់យើងដោយសារយើងបម្រើគាត់ នោះយើងអាចបម្រើពួកគាត់បាន ប៉ុន្តែយើងមិនអាចស្រឡាញ់ពួកគាត់បានទេ។ ប្រសិនបើឪពុកម្ដាយនិយាយទៅកាន់កូនថា «ប៉ាម៉ាក់នឹងស្រឡាញ់កូនលុះត្រាតែកូនទទួលបានពិន្ទុនិទ្ទេស A ក្នុងមុខវិជ្ជាគណិត ស្រោចផ្កា និងដាក់ចំណីឲ្យសត្វស៊ី» នោះកូនទំនងជាស្ដាប់បង្គាប់ ប៉ុន្តែជាចុងក្រោយគាត់នឹងមិនស្រឡាញ់បុគ្គលដែលស្រឡាញ់ដោយមានការកេងប្រវ័ញ្ចឡើយ។

ដូចគ្នានោះដែរ ព្រះអម្ចាស់ដែលទាមទារឲ្យយើងស្រឡាញ់ទ្រង់ ព្រះអង្គក៏បានឲ្យយើងអាចធ្វើការនោះបាន តាមរយៈការដែលទ្រង់ធ្វើឲ្យសេចក្ដីស្រឡាញ់របស់ទ្រង់ក្លាយជាអំណោយទានដែលគ្មានល័ក្ខខ័ណ្ឌ។ ព្រះគម្ពីរបានចែងថា «យើងស្រឡាញ់ទ្រង់ ពីព្រោះទ្រង់បានស្រឡាញ់យើងជាមុន» (១យ៉ូហាន ៤:១៩)។ ព្រះជាម្ចាស់គឺជាអង្គដែលបានផ្ដួចផ្ដើមគំនិតក្នុងការបើកបង្ហាញក្ដីស្រឡាញ់ដ៏គ្មានលក្ខខណ្ឌរបស់ទ្រង់។

## *ការតាំងសេចក្ដីសញ្ញាដ៏ស្មោះត្រង់*

តាមរយៈការចែងទុកនូវសេចក្ដីតាំងសញ្ញាដែលព្រះជាម្ចាស់បានធ្វើជាមួយនឹងរាស្ត្ររបស់ទ្រង់ ព្រះគម្ពីរបង្រៀនយើងបន្ថែមទៀតអំពីការដែលព្រះជាម្ចាស់គឺជាអង្គដែលផ្ដើមការស្រឡាញ់។ តាមរយៈការតាំងសញ្ញាបែបនេះ ព្រះជាម្ចាស់សន្យាថា នឹងស្រឡាញ់រាស្ត្ររបស់ទ្រង់ដោយគ្មានលក្ខខណ្ឌ។ ការតាំងសញ្ញាទាំងអស់នេះគឺមិនមែនជាកិច្ចព្រមព្រៀងនោះទេ។ កិច្ចព្រមព្រៀងអាចក្លាយជាការអសារបង់បានប្រសិនបើគេមិនគ្រាប់តាមលក្ខខណ្ឌ

ប៉ុន្តែការខ្វះការបង្ហាញសកម្មភាពនឹងមិនរំសាយចោលនូវសេចក្តីតាំងសញ្ញារបស់ព្រះជាម្ចាស់ឡើយ។ នេះឯងជាមូលហេតុដែលរាស្ត្ររបស់ព្រះជាម្ចាស់អាចនិយាយថា «បើទុកជាយើងមិនស្មោះត្រង់ក៏ដោយ គង់តែទ្រង់នៅតែស្មោះត្រង់ដដែល» (២ធីម៉ូថេ ២:១៣)។

ការរំដោះសាសន៍អ៊ីស្រាអែលចេញពីភាពជាទាសករគឺជាឧទាហរណ៍ដ៏ល្អបំផុតនៃការតាំងសញ្ញានៃសេចក្តីស្រឡាញ់មួយនេះ។ អស់រយៈពេលរាប់សតវត្សមុននោះ ព្រះជាម្ចាស់បានសន្យាថា ទ្រង់នឹងស្រឡាញ់លោក អ័ប្រាហាំ ហើយនិងពូជពង្សរបស់គាត់។ ប៉ុន្តែ ម្តងហើយម្តងទៀត ជាច្រើនលើកច្រើនសារ ពួករាស្ត្រទាំងអស់នោះតែងតែភ្លេចព្រះជាម្ចាស់។ ពួកគាត់បានក្លាយជាទាសករនៅស្រុកអេស៊ីព្ទរហូតទាល់តែព្រះជាម្ចាស់បានចាត់លោក ម៉ូសេ ឲ្យទៅរំដោះពួកគាត់ចេញមក។ បន្ទាប់ពីពេលដែលព្រះជាម្ចាស់បានរំដោះពួកគាត់នោះទើបព្រះអង្គបានប្រទានបញ្ញត្តិដែលអនុញ្ញាតឲ្យពួកសាសន៍អ៊ីស្រាអែលមានលទ្ធភាពក្នុងការរស់នៅដោយបរិសុទ្ធបាន។

លំដាប់លំដោយនៃពេលវេលាដែលព្រឹត្តិការណ៍ទាំងនេះបានកើតឡើងគឺសំខាន់ណាស់សម្រាប់ឲ្យយើងយល់ដឹង ទាក់ទងនឹងសេចក្តីតាំងសញ្ញានៃការស្រឡាញ់របស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់បានរំដោះពួករាស្ត្រមុនព្រះអង្គបានប្រទានក្រឹត្យវិន័យដល់ពួកគាត់។ ព្រះអង្គមិនបានរងចាំឲ្យពួកគាត់ស្តាប់បង្គាប់ទ្រង់មុនព្រះអង្គសង្គ្រោះពួកគាត់នោះទេ (ចោទិយកថា ៥:៦)។ ព្រះអង្គមិនបានមានបន្ទូលថា «ចូរស្តាប់បង្គាប់អញសិន នោះទើបអញនឹងស្រឡាញ់ឯង»។ ក្នុងការតាំងសេចក្តីសញ្ញាដ៏ស្មោះត្រង់ ព្រះអង្គមានបន្ទូលថា «អញបាន

ស្រឡាញ់ឯងរួចស្រេចទៅហើយ ហើយក៏បានរំដោះឯងទៀតផង ដែលនោះហើយគឺជាមូលហេតុដែលឯងគួរត្រាប់តាមក្រឹត្យវិន័យទាំងអស់នេះដែលនឹងប្រទានពរដល់ជីវិតរបស់ឯង»។

ព្រះគុណរបស់ព្រះជាម្ចាស់បានមកកាន់យើង—ការដែលព្រះអង្គស្រឡាញ់យើង ទោះបើមុនយើងស្រឡាញ់ទ្រង់ ឬស្តាប់បង្គាប់ទ្រង់—គឺជាផ្នែកមួយដ៏ចាំបាច់នៃដំណឹងល្អ (រ៉ូម ៥:៨)។ ប្រសិនបើព្រះជាម្ចាស់រង់ចាំឲ្យយើងរៀបរៀងជីវិតយើងឲ្យបានល្អប្រសើរមុននឹងព្រះអង្គស្រឡាញ់យើង នោះនឹងគ្មានសេចក្តីសង្ឃឹមសម្រាប់បុគ្គលដូចប្អូនប្រុសរបស់ខ្ញុំដែលកំពុងជាប់គុកនោះទេ។ ជីវិតរបស់ ដាវីឌ គឺមានពេញទៅដោយវិបត្តិ។ គឺគ្មានផ្លូវទេ ក្នុងការដែលឲ្យគាត់កែតម្រូវកំហុសដែលគាត់បានប្រព្រឹត្ត។ គាត់មិនមានសេរីភាពខាងឯសាច់ឈាម និងការគិតគូរខាងឯស្មារតីក្នុងការបង្វែរនូវការខូចខាតដែលគាត់បានប្រព្រឹត្តចំពោះអ្នកដទៃ។ ប៉ុន្តែ នៅពេលដែលគាត់ទទួលស្គាល់នូវសេចក្តីពិតដែលថា ព្រះយេស៊ូវស្រឡាញ់គាត់ ហើយនឹងជួយគាត់ នោះប្អូនប្រុសខ្ញុំអាចទទួលបាននូវព្រះគុណរបស់ព្រះគ្រីស្ទបាន ទោះបើគាត់បានប្រព្រឹត្តអំពើបាបជាច្រើនឆ្នាំ ហើយគាត់មានជីវិតមួយដែលពេញទៅដោយអសមត្ថភាពក៏ដោយ។

ពេញមួយជីវិតជំទង់របស់ ដាវីឌ គាត់តែងតែនិយាយទៅកាន់គ្រួសាររបស់គាត់ក្នុងប្រយោគយ៉ាងសាមញ្ញៗ ឬក៏ស្រែកថ្ងូរតែប៉ុណ្ណោះ។ ប៉ុន្តែ នៅពេលដែលគាត់ជឿទុកចិត្តលើក្តីស្រឡាញ់របស់ព្រះយេស៊ូវសម្រាប់គាត់ ដាវីឌ ក៏ចាប់ផ្តើមផ្ញើសំបុត្រមកកាន់ពួកយើង។ យើងមិនទាំងដឹងផងថា គាត់អាចសរសេរបាន។ ការសរសេរ និងវេយ្យាករណ៍គឺដូចក្មេងៗ ប៉ុន្តែខណៈពេលដែលពេល

វេលាកន្លងផុតទៅ ការសរសេររបស់គាត់ក៏កាន់តែល្អជាងមុន—ដូចនឹងជំនឿលទ្ធភាពរបស់ ដាវីឌ ក្នុងការពណ៌នាជំនឿរបស់គាត់។ គាត់បានសរសេរពីក្នុងគុកថា «ព្រះជាម្ចាស់អាចធ្វើការអស្ចារ្យសម្រាប់មនុស្សគ្រប់ៗគ្នាដែលជឿលើទ្រង់បាន។ ញ៉ុមជឿព្រះ។ ព្រះអង្គបានចាត់បុត្ររបស់ទ្រង់ឈ្មោះ យេស៊ូវ ឲ្យមកស្លាប់សម្រាប់បាបយើង។ ព្រះស្រឡាញ់ពិភពលោកខ្លាំងណាស់ រហូតដល់ព្រះអង្គឲ្យកូនតែមួយគត់របស់ទ្រង់។ អ្នកណាដែលជឿលើទ្រង់នឹងមិនស្លាប់ទេ តែមានជីវិតអស់កល្បជានិច្ច។»

ដាវីឌ បានប្រាប់មនុស្សគ្រប់គ្នាថា គាត់ស្គាល់អំពីដំណឹងល្អរបស់ព្រះគ្រីស្ទតាមរយៈការដែលគាត់សម្រួលកណ្ឌគម្ពីរ យ៉ូហាន ៣:១៦ ដោយប្រើពាក្យពេចន៍ផ្ទាល់ខ្លួន៖ ដំណឹងល្អគឺធំល្មមសម្រាប់ពិភពលោកទាំងមូល វាធំល្មមសម្រាប់រាល់អំពើបាបរបស់យើង ហើយអស់អ្នកណាដែលទទួលជឿទ្រង់ ក៏អាចទទួលសេចក្តីសង្គ្រោះបានដែរ។

## *ជំនឿលើព្រះគ្រីស្ទ*

អស់អ្នកណាដែលទទួលជឿលើព្រះគ្រីស្ទអាចទទួលដំណឹងល្អបាន។ ព្រះជាម្ចាស់មិនបានមានព្រះបន្ទូលថា ទ្រង់នឹងសង្គ្រោះអស់អ្នកណាដែលធ្វើអ្វីអស្ចារ្យសិន ផ្តាច់នូវការញៀនរបស់ពួកគាត់ចោលជាមុន ឬក៏ជួយបណ្តោះភាពក្រីក្រតោកយ៉ាកចោល ឬក៏ឈោងទៅដល់កម្រិតនៃសេចក្តីល្អណាមួយដែលមានការពណ៌នាមុនពេលព្រះអង្គសង្គ្រោះពួកគាត់នោះឡើយ។ ព្រះអង្គសង្គ្រោះអស់អ្នកណាដែលទុកចិត្តយ៉ាងសាមញ្ញលើព្រះយេស៊ូវ ទុកជាព្រះអង្គសង្គ្រោះរបស់ពួកគាត់ (យ៉ូហាន ៣:១៦)។

ស្ថានភាពរបស់ ដាវីឌ ជួយឲ្យយើងយល់អំពីលក្ខណៈនៃជំនឿបែបនោះ។ យើងមិនគួរទទួលការបញ្ចុះបញ្ចូលឲ្យមានការយល់ដឹងយ៉ាងខុសឆ្គងដែលថា ជំនឿក្នុងព្រះគ្រីស្ទឃើញនូវអ្វីមួយដែលល្អនៅក្នុងយើង ដែលការនោះធ្វើឲ្យទ្រង់ស្រឡាញ់យើងនោះឡើយ។ បើយោងតាមគំនិតបែបនេះ ជំនឿគ្រាន់តែធ្វើឲ្យយើងបានល្អជាងមុនតែបន្តិចលើសពីអ្នកដទៃតែប៉ុណ្ណោះ។ ប៉ុន្តែ អត្ថន័យលើពាក្យជំនឿបែបនោះ គឺមិនសមហេតុសមផលទេ។ តើឲ្យការធ្វើនូវអ្វីមួយដ៏តូចតាចទទួលស្គាល់ថាព្រះគ្រីស្ទសុគតសម្រាប់អំពើបាបអាចមានលទ្ធភាពមកទូទាត់នឹងការដែលសាវ័ក ប៉ុល បានជេរប្រមាថ និងសម្លាប់បានដោយរបៀបណាទៅ? តើឲ្យជំនឿដ៏សាមញ្ញរបស់ប្អូនប្រុសខ្ញុំលើយញ្ញបូជារបស់ព្រះគ្រីស្ទមកទូទាត់អំពើឧក្រិដ្ឋពីអតីតកាលរបស់គាត់បានដោយរបៀបណា? ប្រសិនបើព្រះជាម្ចាស់ថ្លឹងថ្លែងដោយប្រើជញ្ជីងនៃភាពយុត្តិធម៌ជាមួយនឹងជំនឿរបស់យើង នោះព្រះអង្គនឹងមិនមានភាពយុត្តិធម៌ឡើយ។ ដាច់ខាត! យើងត្រូវតែយល់ថា យញ្ញបូជារបស់ព្រះគ្រីស្ទ—មិនមែនជំនឿរបស់យើង—គឺជាព័ន្ធកិច្ចដែលថ្លឹងថ្លែងដោយប្រើប្រាស់ជញ្ជីងនៃភាពយុត្តិធម៌របស់ព្រះជាម្ចាស់វិញ។

ប្រសិនបើជំនឿរបស់យើងទិញព្រះគុណរបស់ព្រះជាម្ចាស់បាន នោះមានន័យថា យើងមានទំនួលខុសត្រូវសម្រាប់សេចក្តីសង្គ្រោះរបស់យើងហើយ។ យើងអាចរាប់ថា ខ្លួនជាអ្នកសម្រេច។ ប៉ុន្តែ ព្រះគម្ពីរមានចែងយ៉ាងច្បាស់លាស់ថា៖ ព្រះយេស៊ូវសង្គ្រោះ។ ជំនឿរបស់យើងមិនអាចទិញក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ឬក៏នាំឲ្យយើងអាចទិញព្រះគុណរបស់ទ្រង់បានឡើយ។ ឧទាហរណ៍៖ ប្រសិនបើជាបុរសម្នាក់ដែលគាត់ទទួលបានការសង្គ្រោះពីការ

លង់ទឹកកំពុងរត់នៅលើឆ្នេរសមុទ្រហើយអួតអាងថា «ខ្ញុំនៅមានជីវិត ពីព្រោះខ្ញុំល្អគ្រប់គ្រាន់ក្នុងការស្រែកហៅឲ្យអ្នកយាមឆ្នេរមកសង្គ្រោះខ្ញុំ» នោះពិតជារឿងប្លែកមែន! គ្រប់ៗគ្នានឹងទទួលស្គាល់ថា អ្នកហែលទឹកដែលគេទើបតែបានសង្គ្រោះនោះគ្មានសិទ្ធិក្នុងការអួតខ្លួនទេ។ ការដែលគាត់ទទួលបានការសង្គ្រោះគឺជាលទ្ធផលនៃការពឹងអាស្រ័យទាំងស្រុងលើឆន្ទៈល្អ និងសមត្ថភាពនៃអ្នកយាមឆ្នេរ។

ការរំពឹងអាស្រ័យលើបុគ្គលណាម្នាក់ទាំងស្រុងគឺជាចំណុចផ្ទុយគ្នានៃការយល់ដឹងមិនត្រឹមត្រូវ។ ចំណុចទីពីរគឺទាក់ទងនឹងជំនឿដែលសង្គ្រោះ៖ វាអាចល្មមគ្រប់គ្រាន់តាមរយៈកម្លាំងរបស់វា។ គេគិតថា តាមរយៈការមានលក្ខណៈល្មមគ្រប់គ្រាន់ ទាក់ទងនឹងសមត្ថភាពនៃការគិតគូរ ឬក៏ការសិក្សាខាងផ្នែកទេវវិទ្យា នោះពួកគាត់អាចនឹងបង្កើតឲ្យមានជំនឿល្មមគ្រប់គ្រាន់ក្នុងចិត្តខ្លួនដើម្បីទាក់ទាញឲ្យព្រះជាម្ចាស់ស្រឡាញ់ពួកគាត់។ ប៉ុន្តែ ការគិតថាសេចក្តីសង្គ្រោះរំពឹងលើការដែលយើងមានជំនឿដ៏ខ្ពស់គ្រាន់តែជារបៀបនៃការធ្វើឲ្យជំនឿក្លាយទៅជាអ្វីមួយដែលយើងត្រូវការធ្វើ ដើម្បីបានល្អប្រសើរជាងអ្នកដទៃតែប៉ុណ្ណោះ។ ចំណុចនេះប្រៀបដូចជាអ្នកហែលទឹកដែលអួតលើឆ្នេរថា «ខ្ញុំបានសង្គ្រោះ ព្រោះខ្ញុំបានតោងអ្នកយាមឆ្នេរដោយប្រើកម្លាំងយ៉ាងខ្លាំងក្លាដែលខ្ញុំមានជាងអ្នកដទៃ»។

ដើម្បីឲ្យយើងយល់ពីជំនឿតាមបែបព្រះគម្ពីរបាន ដាច់ខាតយើងត្រូវតែរាប់ខ្លួនឯងថា យើងអស់កម្លាំងទាំងស្រុងយ៉ាងល្ហិតល្ហៃពីការព្យាយាមនៅរស់ខាងឯព្រលឹងវិញ្ញាណ ហើយពឹងអាស្រ័យទាំងស្រុងលើកម្លាំងអ្នកយាម

ឆ្មេរ (ព្រះយេស៊ូវ) ក្នុងការសង្គ្រោះយើង។ ក្តីសង្ឃឹមរបស់យើងមិនអាចមានមូលដ្ឋានលើកម្លាំងនៃជំនឿរបស់យើងបានទេ—រលកនៃភាពទន់ខ្សោយ និងមន្ទិលសង្ស័យគឺខ្លាំងពេកណាស់ហើយសម្រាប់ការនោះ។ ទេ! ប៉ុន្តែផ្ទុយទៅវិញ ក្តីសង្ឃឹមរបស់យើងគឺមានមូលដ្ឋានលើការប្រទានឲ្យរបស់ព្រះយេស៊ូវតែមួយគត់ទេតើ។

ដោយនឹកស្រមៃឃើញប្អូនប្រុសរបស់ខ្ញុំដែលកំពុងឱបដៃឱបជើងនៅកន្លៀតក្នុងបន្ទប់គុក ហើយថែមទាំងមានព្រំដែនលើលទ្ធភាពនៃការគិតគូរ អស់កម្លាំងយ៉ាងល្អិតល្អៃខាងឯអារម្មណ៍ ហើយមានពេញទៅដោយពិរុទ្ធភាពយ៉ាងធ្ងន់ធ្ងរនោះខ្ញុំមិនចង់គិតថាមូលដ្ឋាននៃសេចក្តីសង្ឃឹមរបស់គាត់គឺពឹងលើកម្លាំងនៃជំនឿរបស់គាត់ឡើយ។ ខ្ញុំចង់ឲ្យក្តីសង្ឃឹមរបស់គាត់មានមូលដ្ឋានលើកម្លាំងនៃក្តីស្រឡាញ់របស់ព្រះយេស៊ូវវិញ។ ដាវីឌ មិនមានកម្លាំងខាងឯការគិតគូរ ឬក៏ក្នុងចិត្តសម្រាប់អ្វីផ្សេងទៀតទេ។ ដាច់ខាត! ក្តីសង្ឃឹមរបស់គាត់គឺត្រូវដូចគ្នាទៅនឹងក្តីសង្ឃឹមរបស់សាវ័ក ប៉ុល ដែលស្គាល់ពីអត្ថន័យដែលថាគាត់បានឈានមកដល់ចំណុចបញ្ចប់នៃប្រាជ្ញា ភាពឆេះឆួល និងកម្លាំងរបស់គាត់ទុកជាមូលដ្ឋានសម្រាប់ឲ្យព្រះជាម្ចាស់អនុម័តដែរ។ សាវ័ក ប៉ុល បានសរសេរថា «ដ្បិតគឺដោយព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះដោយសារជំនឿ ហើយសេចក្តីនោះក៏មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ ក៏មិនមែនដោយការប្រព្រឹត្តដែរ ក្រែងអ្នកណាអួតខ្លួន» (អេភេសូរ ២:៨-៩)។

ជំនឿគឺមិនមែនជាការប្រព្រឹត្ត ឬក៏ការហ្វឹកហាត់ខាងឯការគិតគូរ ឬជាការដកពិសោធន៍ខាងឯផ្នែកអារម្មណ៍ទេ។ យើងមិនអាចអួតថា យើងមាន

ជំនឿគ្រប់គ្រាន់ល្មម ដើម្បីអាចទទួលបានសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ឡើយ។ ជំនឿដែលនាំឲ្យមានសេចក្ដីសង្គ្រោះគឺជាការរៀបរាប់អំពីការដែលមនុស្សយើងចុះចូល និងជាការទទួលស្គាល់ថា គ្មានអ្វីចេញពីយើងដែលគួរធ្វើឲ្យព្រះជាម្ចាស់ស្រឡាញ់យើងសោះ។ យើងពឹងលើព្រះយេស៊ូវតែមួយអង្គគត់ ដើម្បីឲ្យសង្គ្រោះយើងចេញពីអំពើបាប។ យើងមិនជឿថាមានអ្វីដែលយើងអាចនឹងធ្វើល្មមគ្រប់គ្រាន់ ដើម្បីធ្វើឲ្យព្រះជាម្ចាស់ស្រឡាញ់យើង—មិនមែនអំពើល្អរបស់យើង មិនមែនគំនិតដែលមានពេញដោយប្រាជ្ញារបស់យើង ហើយថែមទាំងមិនមែនកម្លាំងនៃជំនឿរបស់យើងទៀតផង។ យើងគ្រាន់តែជឿទុកចិត្តថាព្រះយេស៊ូវគឺជាព្រះសង្គ្រោះតែប៉ុណ្ណោះ។

ជំនឿក្នុងព្រះគ្រីស្ទតែមួយគត់—ការលះបង់ខ្លួនថាជាមូលដ្ឋានដែលនាំឲ្យព្រះជាម្ចាស់អនុម័តលើយើង—គឺជាលទ្ធផលនៃព័ន្ធកិច្ចរបស់ព្រះជាម្ចាស់ក្នុងចិត្តរបស់យើងដែលទ្រង់ប្រើប្រាស់នូវរាល់ចំណុចនៃការអស់សង្ឃឹម និងចំណុចនៃការខកចិត្តរបស់យើងមិនមានមូលដ្ឋាននៃក្ដីសង្ឃឹមណាទៀត លើកលែងតែលើព្រះយេស៊ូវនោះយើងនឹងបង្វែរចេញពីរាល់គ្រប់អ្វីៗទាំងអស់ទៅរកទ្រង់វិញជាមិនខាន។ នេះឯងជាមូលហេតុមួយដែលសាវ័ក ប៉ុល បានមានប្រសាសន៍ថា សូម្បីតែជំនឿដែលយើងមានក៏ជាអំណោយទានពីព្រះជាម្ចាស់ដែរ (អេភេសូរ ២:៨-៩)។ ជំនឿដែលនាំឲ្យមានការសង្គ្រោះគឺមិនមែនជាអ្វីមួយដែលយើងធ្វើដោយប្រឹងប្រែងលើកម្លាំងខ្លួនឯងទេ។ ប្រសិនបើព្រះជាម្ចាស់មិនធ្វើឲ្យចង្វាក់បេះដូងរបស់យើងលោតសម្រាប់ព្រះអង្គ នោះយើងនឹងប្រាកដជាស្លាប់ខាងឯវិញ្ញាណជាមិនខាន (អេសេគាល ៣៦:២៦; អេភេសូរ ២:១)។

## *ចូរសម្រាកក្នុងព្រះគ្រីស្ទ*

ជំនឿតាមបែបព្រះគម្ពីរគឺមិនសូវពាក់ព័ន្ធក្នុងការទុកចិត្តលើឋានៈនៃចំណេះដឹងរបស់យើង ភាពក្លៀវក្លាឬលើការស្ដីបន្ទោសខ្លួនឯងប៉ុន្មានទេ ប៉ុន្តែគឺពឹងអាស្រ័យដ៏សាមញ្ញលើព័ន្ធកិច្ចរបស់ព្រះគ្រីស្ទវិញ។ យើងមិនអាចរំពឹងលើកម្លាំងនៃជំនឿរបស់យើងក្នុងការតោងព្រះអង្គនោះទេ ប៉ុន្តែគឺពឹងលើកម្លាំងនៃសេចក្ដីស្រឡាញ់របស់ព្រះអង្គក្នុងការលើកយើងឡើងទៅកាន់ព្រះអង្គផ្ទាល់។ វាប្រៀបដូចជាបុរសដ៏ខ្លាំងណាម្នាក់ដែលចូលជិះជណ្ដើរយន្ត គាត់មិនពឹងអាងលើសាច់ដុំរបស់គាត់ទេ ប៉ុន្តែគាត់ពឹងអាងលើខ្សែកាបខាងលើក្នុងការទាញគាត់ឡើង។ ដូចគ្នានេះដែរ ជំនឿតាមបែបព្រះគម្ពីរគឺមិនពឹងអាស្រ័យលើការបញ្ចេញការប្រឹងប្រែងខាងវិញ្ញាណរបស់យើងឡើយ ប៉ុន្តែពឹងលើការសម្ដែងភាពអាស្រ័យខាងវិញ្ញាណរបស់យើងវិញ។ យើងក៏មិនសូវរំពឹងលើជំនឿដ៏អស្ចារ្យរបស់យើងក្នុងព្រះគ្រីស្ទប៉ុន្មានទេ តែផ្ទុយទៅវិញ យើងសម្រាកក្នុងសេចក្ដីស្រឡាញ់ដ៏អស្ចារ្យរបស់ទ្រង់សម្រាប់យើង (អេសាយ ៣០:១៥; ហេព្រើរ ៤:៩-១១)។ យើងទុកចិត្តលើសេចក្ដីមេត្តាករុណាដ៏នៅអស់កល្បជានិច្ច និងមិនចេះប្រែប្រួលនៃព្រះដ៏មានពេញទៅដោយអំណាចព្រះចេស្ដា មិនមែនលើភាពមិនគ្រប់គ្រាន់លាយជាមួយនឹងការខិតខំប្រឹងប្រែងដែលកើតចេញពីសាច់ឈាមរបស់យើង។

ខណៈពេលដែលយើងបើកចំហចិត្តយើងទៅកាន់ធាតុពិតនៃសេចក្ដីស្រឡាញ់ដែលគ្មានលក្ខខណ្ឌរបស់ព្រះជាម្ចាស់ នោះយើងនឹងរកឃើញភាពផ្អែមល្ហែម និងសន្តិភាពដ៏គួរឲ្យភ្ញាក់ផ្អើលជាមិនខាន (រ៉ូម ៥:១-២)។ ជាជាងការ

ខ្វាយខ្វល់យ៉ាងឥតល្ហែអំពីការព្យាយាមបំពេញសេចក្ដីរំពឹងរបស់ព្រះជាម្ចាស់ ឬក៏រម្ងាប់សេចក្ដីក្រោធរបស់ទ្រង់ នោះមនុស្សយើងរកឃើញការដែលព្រះអង្គទទួលយើងយ៉ាងឥតឈប់ឈរ (អេភេសូរ ២:១៧-១៩)។ យើងក៏នឹងរកឃើញផងដែរថា នៅពេលដែលយើងអនុញ្ញាតឲ្យព្រះយេស៊ូវមានទំនួលខុសត្រូវលើព្រលឹងរបស់យើង នោះការរស់នៅជាប្រចាំថ្ងៃរបស់យើងគឺមិនមែនរស់នៅក្នុងការថាព្រះជាម្ចាស់ខុនព្រះទ័យនឹងយើងនោះឡើយ។ ដោយសារជំនឿរបស់យើងនៅក្នុងព័ន្ធកិច្ចនៃការសង្គ្រោះរបស់ព្រះគ្រីស្ទតែមួយគត់ នោះជីវិតជាគ្រីស្ទបរិស័ទនឹងលែងនៅដូចជាការនឿយហត់ក្នុងការរត់លើម៉ាស៊ីនហាត់ប្រាណ ដើម្បីព្យាយាមធ្វើឲ្យព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងទង្វើរបស់យើងនោះទេ។ យើងសម្រាកក្នុងព្រះគុណដែលគ្របបាំងអំពើបាបរបស់យើង ដែលបានយកឈ្នះលើការបរាជ័យរបស់យើង ហើយក៏បានប្រទានមកកាន់យើងនូវសេចក្ដីសុចរិតរបស់ព្រះយេស៊ូវផងដែរ។

យើងនឹងលែងនៅបន្តខិតខំប្រឹងប្រែង ដើម្បីធ្វើឲ្យព្រះជាម្ចាស់ស្រឡាញ់យើងទៀតហើយ។ ព្រះអង្គស្រឡាញ់យើង ហើយប្រសិនបើស្ដេចនៃស្ថានសួគ៌ញញឹមដាក់យើង នោះយើងមិនចាំបាច់អស់សង្ឃឹមដោយបារម្ភថា មានអ្នកខ្លះមិនបានពេញចិត្តនឹងយើង ឬក៏ថាកាលៈទេសៈរបស់យើងមើលទៅហាក់បីដូចជាមិនគួរឲ្យខកចិត្តនោះទេ។ ព្រះគុណរបស់ព្រះជាម្ចាស់ធ្វើឲ្យយើងមានសេចក្ដីសុចរិតដូចដែលព្រះយេស៊ូវមាននៅចំពោះព្រះវរបិតាដែរ មិនថាយើងមានអំពើបាបធំ ឬក៏តូចប៉ុណ្ណោ មិនថាយើងជឿថាជីវិតរបស់យើងឥតប្រយោជន៍ ឬក៏ថាពេញបរិបូណ៌ពេក ឬក៏ថាយើងរស់នៅក្នុងផ្ទះដ៏ស្អាត ឬក៏ក្នុងគុកក៏

ដោយ។ ព្រះអង្គស្រឡាញ់យើងដូចដែលព្រះអង្គស្រឡាញ់ព្រះយេស៊ូវដែរ។ ចំពោះអស់អ្នកដែលបានកាន់ទុក្ខលើពិរុទ្ធភាពរបស់ខ្លួន សោកស្តាយលើការបរាជ័យរបស់ខ្លួន ហើយខ្លាចអនាគតរបស់ខ្លួន ក្តីស្រឡាញ់ដ៏អស្ចារ្យមួយនេះគឺជាការផ្តល់ឲ្យដ៏កក់ក្តៅបំផុតក្នុងការឲ្យយើងសម្រាកលើ។ ប៉ុន្តែ ក៏នៅមានដំណឹងថែមទៀតក្នុងដំណឹងដ៏ល្អនេះ។

## អ្វីដែលព្រះជាម្ចាស់ប្រទានឲ្យ ទ្រង់ធ្វើឲ្យល្អឥតខ្ចោះ

ការទទួលការរាប់ជាសុចរិតដោយព្រះគុណគឺជាការដ៏អស្ចារ្យ ប៉ុន្តែផែនការរបស់ព្រះជាម្ចាស់មិនមានត្រឹមតែប៉ុណ្ណោះឡើយ។ ព្រះយេស៊ូវគ្រីស្ទមិនគ្រាន់តែបានរំដោះយើងចេញពីអំពើបាបនៅអតីតកាលនោះទេ ប៉ុន្តែក៏ថែមទាំងធានាឲ្យយើងមានជីវិតអស់កល្បជានិច្ចជាមួយនឹងទ្រង់ផងដែរ។ នេះហើយជាមូលហេតុដែលព្រះយេស៊ូវមានបន្ទូលថា អស់អ្នកណាដែលទទួលជឿទ្រង់ «មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ» (យ៉ូហាន ៣:១៦)។ សេចក្តីសង្គ្រោះរបស់ព្រះជាម្ចាស់មិនមែនដូចជាការទទួលបានការសង្គ្រោះពីការវាយប្រហារពីសត្វខ្លានៅថ្ងៃណាមួយ ហើយបន្ទាប់មកថ្ងៃស្អែកត្រូវបានគេបោះចូលទៅក្នុងព្រៃម្តងទៀតឡើយ។ ដំណឹងល្អមានរួមបញ្ចូលទាំងវិធីដែលព្រះជាម្ចាស់នឹងរក្សាយើងទុកឲ្យមានសុវត្ថិភាពខាងឯវិញ្ញាណយ៉ាងអស់ កល្បជានិច្ចផងដែរ។

## ការរួបរួមជាមួយព្រះគ្រីស្ទ

ព្រះជាម្ចាស់មិនគ្រាន់តែស្រឡាញ់យើងដូចដែលព្រះអង្គស្រឡាញ់ព្រះយេស៊ូវប៉ុណ្ណោះទេ ប៉ុន្តែព្រះគុណរបស់ទ្រង់ក៏ថែមទាំងធ្វើឲ្យយើងក្លាយទៅជាបុត្រាបុត្រីរបស់ព្រះអង្គដែរ។ សាវ័ក យ៉ូហាន បានសរសេរដូចតទៅ «មើល៍! ព្រះវរបិតាបានប្រទានសេចក្តីស្រឡាញ់យ៉ាងណាដល់យើង ដែលយើងមានឈ្មោះថាជាកូនរបស់ព្រះ ហើយយើងពិតជាកូនរបស់ព្រះអង្គមែន!» (១យ៉ូហាន ៣:១ គកស)។ ប៉ុន្តែ តើឲ្យនរណាក្នុងចំណោមយើងអាចធ្វើជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់បាន ខណៈពេលដែលយើងបានកើតពីឪពុកម្តាយខាងឯសាច់ឈាមរបស់យើង? ចម្លើយលើសំណួរនេះបង្ហាញយើងថា ព្រះគុណគឺពិតជាអស្ចារ្យមែន៖ ព្រះវរបិតាដែលគង់នៅស្ថានសួគ៌បានយកយើងមកធ្វើកូនចិញ្ចឹមរបស់ទ្រង់ (អេភេសូរ ១:៥-៦)។

តើការយកយើងមកធ្វើជាកូនចិញ្ចឹមមានដំណើរការយ៉ាងដូចម្តេចទៅ? យើងបានពណ៌នារួចស្រេចទៅហើយអំពីចំណុចសំខាន់នៃដំណើរការនោះ៖ យើងពឹងលើព្រះគ្រីស្ទសម្រាប់ជីវិតខាងឯព្រលឹងវិញ្ញាណរបស់យើងជាមួយនឹងព្រះជាម្ចាស់។ យើងធ្វើការនោះតាមរយៈការទទួលស្គាល់ថា យើងត្រូវការព្រះយេស៊ូវក្នុងការធ្វើឲ្យយើងបរិសុទ្ធ ការទទួលស្គាល់នូវអំពើបាបរបស់យើង លទ្ធភាពមិនល្អមគ្រប់គ្រាន់នៃការគិត ពាក្យពេចន៍ និងទង្វើរបស់យើង ដើម្បីធ្វើឲ្យយើងអាចជានាជាមួយនឹងព្រះជាម្ចាស់បាន។ បន្ទាប់មក ព្រះជាម្ចាស់រាប់យើងជាសុចរិត តាមរយៈព្រះគុណរបស់ទ្រង់តែមួយគត់ ហើយចំពោះព្រះអង្គយើងនឹងក្លាយជាសុចរិត ហើយទ្រង់ក៏នឹងស្រឡាញ់យើងដូចជាទ្រង់

ស្រឡាញ់ព្រះយេស៊ូវដែរ។

យើងមិនទាន់បានវែកញែកអំពីផលប៉ះពាល់ដ៏ពេញទីនៃការពឹងផ្អែកខាងឯព្រលឹងវិញ្ញាណទាំងស្រុងនៅឡើយទេ។ ប្រសិនបើការខិតខំប្រឹងប្រែងរបស់យើងមិនអាចបង្កើតនូវអ្វីមួយសម្រាប់ជីវិតខាងឯព្រលឹងវិញ្ញាណជាមួយនឹងព្រះជាម្ចាស់បាននោះទេ នោះមានន័យថា តាមស្តង់ដារនៃការសម្រេចអ្វីមួយបានរបស់មនុស្សលោកយើងគឺយើងនឹងប្រាកដជាស្លាប់មិនខាន។ ទោះបើថាមើលទៅវាហាក់បីដូចជាប្លែកណាស់ក៏ដោយ ក៏ដំណឹងល្អនៅតែលើកឡើងថាសេចក្តីសន្និដ្ឋានមួយនេះ គឺត្រូវទាំងស្រុង។ ហើយការស្លាប់មួយនេះ គឺតាមពិតទៅជាទ្វារទៅកាន់ជីវិតថ្មីក្នុងគ្រួសាររបស់ព្រះជាម្ចាស់។

*ការរួបរួមក្នុងការសុគតរបស់ព្រះគ្រីស្ទ*

បន្ទាប់ពីសាវ័ក ប៉ុល បានសន្និដ្ឋានថា ការប្រមូលទង្វើល្អនឹងមិនអាចនាំបុគ្គលណាម្នាក់ឲ្យត្រូវបានរាប់ជាសុចរិតនៅចំពោះព្រះភក្ត្រនៃព្រះដ៏បរិសុទ្ធបានទេ គាត់បានសរសេរថែមទៀតថា «ខ្ញុំបានជាប់ឆ្កាងជាមួយព្រះគ្រីស្ទដូច្នេះ មិនមែនខ្ញុំទៀតទេដែលរស់នៅ» (កាឡាទី ២:២០ គកស)។ ទោះបើថាពេលស្តាប់ទៅពាក្យពេចន៍ទាំងនោះអាក្រក់ណាស់ក៏ដោយ ក៏វានៅតែជាសេចក្តីសន្និដ្ឋានដ៏ត្រឹមត្រូវនៃជីវិតដែលឈរនៅចំពោះព្រះភក្ត្ររបស់ព្រះជាម្ចាស់ដោយមានមូលដ្ឋានលើយញ្ញបូជារបស់ព្រះយេស៊ូវជាជាងលើភាពបរិសុទ្ធរបស់ខ្លួនឯងផ្ទាល់ដែរ។ សេចក្តីសង្ឃឹមរបស់យើងគឺស្ថិតនៅលើអ្វីដែលព្រះអង្គបានសម្រេចឡើង មិនមែនលើអ្វីដែលយើងធ្វើនោះទេ។ មូលដ្ឋានខាងឯព្រលឹងវិញ្ញាណរបស់យើង—អត្តសញ្ញាណរបស់យើង—គឺត្រូវ

បានរុំខ្ចប់នៅក្នុងទ្រូង។

ស្តាប់ទៅទំនងជាអាក្រក់ណាស់ក្នុងការមានការរួបរួមក្នុងសេចក្តីស្លាប់របស់ព្រះគ្រីស្ទ ប៉ុន្តែតាមពិតទៅវាជាចំណុចដ៏ល្អទេតើ។ ប្រសិនបើរាល់អ្វីៗដែលជាការពិតរបស់យើងត្រូវបានជាប់ឆ្កាង នោះមានន័យថា រាល់អំពើបាបរបស់យើង ការមិនអាចឈោងដល់ និងការបរាជ័យរបស់យើងក៏នៅលើឈើឆ្កាងដែរ។ ដោយសាររាល់គ្រប់អ្វីៗដែលអាចញែកយើងចេញខាងឯព្រលឹងវិញ្ញាណពីព្រះជាម្ចាស់បាន គឺនៅលើឈើឆ្កាង នោះមានន័យថា ព្រះអង្គក៏អាចទាញយើងឲ្យមកជិតទ្រូងផ្ទាល់បានដែរ។ ប៉ុន្តែ តើភាពស្និទ្ធស្នាលនោះជាប្រយោជន៍អ្វីទៅ ប្រសិនបើយើងនៅតែស្លាប់ខាងឯព្រលឹងវិញ្ញាណនៅឡើយ? សាវ័ក ប៉ុល ឆ្លើយសំណួរនេះដោយរម្លឹកយើងអំពីជីវិតយើងខាងឯវិញ្ញាណ—អត្តសញ្ញាណរបស់យើងនៅចំពោះព្រះភក្ត្រព្រះជាម្ចាស់—ឥឡូវនេះ គឺមានចេញពីប្រភពផ្សេងមួយទៀត។

*ការរួបរួមជាមួយព្រះជន្មរបស់ព្រះគ្រីស្ទ*

យើងមិនគ្រាន់តែមានការរួបរួមក្នុងការសុគតរបស់ព្រះគ្រីស្ទតែមួយប៉ុណ្ណោះនោះទេ ប៉ុន្តែយើងក៏មានការរួបរួមក្នុងព្រះជន្មរបស់ព្រះគ្រីស្ទផងដែរ។ សាវ័កប៉ុល បានសរសេរថា «ខ្ញុំបានជាប់ឆ្កាងជាមួយព្រះគ្រីស្ទ ដូច្នេះ មិនមែនខ្ញុំទៀតទេដែលរស់នៅ គឺព្រះគ្រីស្ទវិញទេតើដែលរស់នៅក្នុងខ្ញុំ» (កាឡាទី ២:២០ គកស)។ ពាក្យពេចន៍ទាំងនេះមិនគ្រាន់តែធានាមកកាន់យើងអំពីជីវិតថ្មីជាមួយព្រះគ្រីស្ទប៉ុណ្ណោះទេ ប៉ុន្តែក៏ថែមទាំងផ្តល់លើទស្សនៈនៃចំណុចគន្លឹះមួយនៃដំណឹងល្អដែលយើងមិនសូវជាបានលើកឡើងនៅឡើយ៖ ការរស់ឡើងវិញ។

នៅពេលដែលព្រះយេស៊ូវបានរងទុក្ខនៅលើឈើឆ្កាងជំនួសអំពើបាបរបស់យើង ព្រះអង្គក៏បានលុបចោលនៅទារុណកម្មដែលមាន នៅគ្រាដែលមនុស្សលោកយើងបានបោះបង់ចោលនូវផ្លូវរបស់ព្រះជាម្ចាស់ជាលើកដំបូងដែរ។ ព្រះជាម្ចាស់បានប្រាប់លោក អ័ដាម ថាប្រសិនបើគាត់មិនស្ដាប់បង្គាប់នោះលោក អ័ដាម នឹងស្លាប់ជាមិនខាន (លោកុប្បត្តិ ២:១៧)។ អំពើបាបរបស់លោក អ័ដាម បានបំបាក់នូវភាពស្និទ្ធស្នាលនៃជីវិតចោលរវាងព្រះដ៏បរិសុទ្ធ និងដួងចិត្តរបស់មនុស្ស។ ព្រះជាម្ចាស់បានឆ្លើយតបតាមរយៈការដែលព្រះអង្គប្រោសឲ្យព្រះយេស៊ូវរស់ពីសុគតឡើងវិញ ដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ ដើម្បីបង្ហាញថា ឥទ្ធិពលនៃអំពើបាបដំបូងនេះគឺពិតជាត្រូវបានលុបចោលតាមរយៈយញ្ញបូជារបស់ព្រះគ្រីស្ទមែន (រ៉ូម ៨:១១; ១កូរិនថូស ១៥:១៥-២០)។

បន្ទាប់ពីការសុគត ព្រះជន្មរបស់ព្រះយេស៊ូវបានផ្ដល់ជាភស្ដុតាងថា ទាំងក្ដីសន្យារបស់ព្រះជាម្ចាស់ក្នុងការលុបអំពើបាបចោល និងទាំងការផ្ដល់ជីវិតដ៏នៅអស់កល្បជានិច្ចគឺជាការពិតមែនសម្រាប់យើង។ អំពើបាបរបស់យើងនឹងមិនបំផ្លាញទំនាក់ទំនងរបស់យើងជាមួយនឹងព្រះជាម្ចាស់ចោលនោះទេ ហើយចំណុចចុងក្រោយនៃជីវិតយើងលើផែនដីនេះក៏នឹងមិនបំផ្លាញនូវទំនាក់ទំនងរបស់យើងជាមួយនឹងព្រះជាម្ចាស់ដែរ។ នៅពេលដែលរូបកាយខាងឯសាច់ឈាមរបស់យើង ស្លាប់ទៅ នោះជីវិតខាងឯវិញ្ញាណរបស់យើងនឹងនៅបន្តក្នុងការប្រកបគ្នាជាមួយនឹងព្រះអម្ចាស់ដ៏នៅអស់កល្បជានិច្ច។ ហើយក៏នឹងមានពេលដែលព្រះជាម្ចាស់ប្រោសរូបកាយយើង ដូចដែលទ្រង់បានប្រោសព្រះយេស៊ូវ ដើម្បីឲ្យយើងអាចនឹងរួបរួមក្នុងរូបកាយ និងវិញ្ញាណជាមួយនឹង

ព្រះយេស៊ូវបាន ប៉ុន្តែចំណុចនេះគឺជាដំណឹងល្អដែលយើងនឹងពណ៌នាថែមទៀតនៅបន្តិចទៀតនេះ។

សម្រាប់ឥឡូវនេះ វាជារឿងសំខាន់ណាស់ក្នុងការយល់ថា វិញ្ញាណរបស់អ្នកជឿទាំងអស់គឺត្រូវបានទទួលការរួបរួមជាមួយនឹងព្រះគ្រីស្ទ ដោយសារព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ។ ទោះបើថាព្រះអង្គបានសុគត ឥឡូវនេះព្រះអង្គមានព្រះជន្មរស់ឡើងវិញ ហើយព្រះអង្គគង់នៅក្នុងយើង—ក្នុងការរួបរួមខាងឯវិញ្ញាណជាមួយនឹងព្រលឹងរបស់យើង។ ចូរចងចាំថាសាវ័ក ប៉ុល បានលើកឡើងថា «គឺព្រះគ្រីស្ទវិញទេតើដែលរស់នៅក្នុងខ្ញុំ»។ ប្រសិនបើយើងមិនអាចគេចចេញពីការស្លាប់បានមែន (ដោយសារគ្មានអ្វីដែលយើងអាចធ្វើបានខាងឯព្រលឹងវិញ្ញាណ ដើម្បីឲ្យយើងជានាជាមួយនឹងព្រះជាម្ចាស់បាន) ហើយព្រះយេស៊ូវមានព្រះជន្មគង់នៅក្នុងយើង (ដោយសារវិញ្ញាណព្រះអង្គមានការរួបរួមគ្នាជាមួយនឹងវិញ្ញាណយើង) នោះមានន័យថាយើងមានអត្តសញ្ញាណរបស់ព្រះយេស៊ូវដែរហើយ។ រាល់គ្រប់អ្វីៗដែលពិតអំពីព្រះអង្គ—ព្រះប្រាជ្ញារបស់ទ្រង់ សេចក្តីបរិសុទ្ធរបស់ព្រះអង្គ នឹងសេចក្តីសុចរិត—បានមកជំនួសចំណុចល្ងីល្ងើរបស់យើង អំពើបាបរបស់យើង និងការបះបោររបស់យើង (១កូរិនថូស ១:៣១)។ សាវ័ក ប៉ុល បានមានអំណរយ៉ាងត្រឹមត្រូវថា ព្រះគ្រីស្ទគឺជាជីវិតនៃយើង (កូឡូស ៣:៤) ហើយ «ដ្បិតសម្រាប់ខ្ញុំ ដែលរស់គឺសម្រាប់ព្រះគ្រីស្ទ» (ភីលីព ១:២១)។ តាមរយៈការរួបរួមគ្នាជាមួយនឹងព្រះគ្រីស្ទខាងឯវិញ្ញាណ នោះរាល់គ្រប់អ្វីៗដែលធ្វើឲ្យយើង

អាម៉ាស់គឺបានស្លាប់អស់ហើយ ហើយរាល់គ្រប់អ្វីៗដែលថ្វាយព្រះកិត្តិយសទៅកាន់ព្រះអង្គក៏ជារបស់យើងដែរ។

## *អភ័យឯកសិទ្ធិក្នុងគ្រួសារ*

ដោយសារយើងមានចំណែកក្នុងអត្តសញ្ញាណរបស់ព្រះគ្រីស្ទ នោះមានន័យថា យើងក៏ជាសមាជិកម្នាក់ក្នុងគ្រួសាររបស់ព្រះជាម្ចាស់ដែរ (ហេព្រើរ ២:១១)។ វាមិនមែនជាបញ្ហានោះទេត្រង់ថា យើងធ្លាប់មានប្រវត្តិអាក្រក់។ អ្វីដែលចាស់ៗ គឺត្រូវបានកន្លងផុតបាត់អស់ទៅហើយ ហើយយើងមានជីវិតថ្មី គឺនៅក្នុងព្រះគ្រីស្ទ (២កូរិនថូស ៥:១៧)។ រាល់គ្រប់បុគ្គលណាដែលមានការរួបរួមគ្នាជាមួយនឹងព្រះគ្រីស្ទ គឺមានសិទ្ធិជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់ដូចព្រះគ្រីស្ទដែរ។ តាមរយៈការយកមកធ្វើជា «កូនចិញ្ចឹម» នោះព្រះជាម្ចាស់បានធានាយ៉ាងពិសេស ដើម្បីជួយយើងឲ្យថ្វាយព្រះកិត្តិយសទៅកាន់ព្រះគ្រីស្ទដែលជាអង្គដែលយើងមានចំណែកក្នុងអត្តសញ្ញាណរបស់ទ្រង់។

*ឋានៈដែលមិនផ្លាស់ប្តូរ*

ការធានាទីមួយគឺថាយើងគ្មានឋានៈដែលផ្លាស់ប្តូរទេ។ នៅពេលដែលគេបានកាត់ក្តីប្អូនប្រុសខ្ញុំទាក់ទងនឹងបទឧក្រិដ្ឋរបស់គាត់ គេបានអនុញ្ញាតឲ្យគ្រួសារខ្ញុំបានជួបជុំគ្នាជាមួយនឹងគាត់ក្នុងបន្ទប់មួយមុនគេយកគាត់ទៅដាក់គុក។ ទាំងសម្រក់ទឹកភ្នែក ឪពុករបស់ខ្ញុំបានលើកឡើងនូវសម្រង់សម្តីចេញពីបទទំនុកតម្កើងចាស់មួយទៅកាន់ប្អូនប្រុសខ្ញុំដែលទើបតែទទួលជឿព្រះអង្គថ្មីៗ ប៉ុន្តែក៏កំពុងតែទៅជាប់គុក ដូចតទៅ៖

«ទោះបើជាប់គុក ក៏វាដូចជារាជវាំងដែរប្រសិនបើព្រះយេស៊ូវគង់នៅជា

មួយខ្ញុំ នៅទីនោះ»។

ដោយលើកឡើងនៅពាក្យពេចន៍ដ៏ទន់ភ្លន់នេះ ឪពុករបស់ខ្ញុំបានបញ្ជាក់អះអាងនូវក្ដីស្រឡាញ់របស់គាត់ក៏ដូចជាការសម្រាលទុក្ខនៃក្ដីស្រឡាញ់របស់ព្រះអម្ចាស់ទៅកាន់ ដាវីឌ។ ទោះបើថា គាត់ទើបតែបានបំបាក់មុខ និងក្បត់ឪពុករបស់ខ្ញុំខ្លាំងប៉ុណ្ណាក៏ដោយក៏ ដាវីឌ នៅតែជាកូនប្រុសរបស់គាត់ដដែល។ ដាវីឌ មិនអាចធ្វើអ្វីមួយដែលអាចបំផ្លាស់បំប្រែទំនាក់ទំនងនោះបានឡើយ។

ដូចគ្នាផងដែរ ទង្វើរបស់យើងក៏មិនអាចបំផ្លាស់បំប្រែទំនាក់ទំនងរបស់យើងជាមួយនឹងព្រះជាម្ចាស់បានដែរ (ហេព្រើរ ១០:១៤)។ ទោះបើពេលយើងប្រព្រឹត្តអំពើបាប និងក្បត់ក្ដីស្រឡាញ់របស់ព្រះអង្គក៏ដោយ ក៏យើងមិនមែនឈប់ធ្វើជាបុត្រាបុត្រីរបស់ទ្រង់ដែរ។ ឋានៈខាងឯព្រលឹងវិញ្ញាណរបស់យើងគឺមិនមែនសន្មតឡើងតាមរយៈអ្វីដែលយើងធ្វើនោះឡើយ ប៉ុន្តែតាមរយៈអ្វីដែលព្រះគ្រីស្ទបានសម្រេចរួចស្រេចទៅហើយទេតើ។ ដោយសារព្រះគ្រីស្ទគង់នៅក្នុងយើង នោះព្រះជាម្ចាស់ស្រឡាញ់យើង។ ការធានាចេញពីក្ដីមេត្តាករុណាដែលគ្មានព្រំដែនរបស់ព្រះអង្គធ្វើឲ្យយើងមានចិត្តប្រាថ្នាចង់ថ្វាយព្រះកិត្តិយសដល់ទ្រង់ ក៏ដូចជាការស្ម័គ្រចិត្តក្នុងការត្រឡប់ទៅកាន់ទ្រង់វិញ ពេលដែលយើងទើបតែបានប្រព្រឹត្តអំពើបាប (រ៉ូម ២:៤)។

ព្រះជាម្ចាស់ទំនងជាប្រដៅប្រដៅយើង ដើម្បីបង្វែរយើងចេញពីផលកម្មដែលអាចមានគ្រោះថ្នាក់យ៉ាងខ្លាំងដែលកើតចេញពីការបះបោររបស់យើង ប៉ុន្តែការកែតម្រង់ខាងឯព្រលឹងវិញ្ញាណមួយនេះគឺមិនមែនដោយសារទ្រង់ស្រឡាញ់យើងតិចជាងមុននោះឡើយ។ គោលបំណងនៃព្រះវរបិតាដែល

គង់នៅស្ថានសួគ៌ក្នុងការផ្ចាញ់ផ្ចាលយើងគឺដើម្បីជួយយើង មិនមែនដើម្បីធ្វើឲ្យយើងឈឺចាប់នោះទេ។ ទោះបើមើលទៅដូចជាយើងកំពុងតែប្រឈមមុខនឹងការផ្ចាញ់ផ្ចាលដោយការឈឺចាប់ខ្លាំងប៉ុនណាពីព្រះជាម្ចាស់ក៏ដោយ ក៏ព្រះអង្គនៅតែស្រឡាញ់យើង ដោយគ្មានព្រំដែន ហើយព្រះអង្គនៅការពារយើងខាងឯព្រលឹងវិញ្ញាណដដែល (ហេព្រើរ ១២:៥-១១)។ ក្នុងនាមជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់ ឋានៈរបស់យើងមិនដែលផ្លាស់ប្រែឡើយ។

*ការការពារដ៏អចិន្ត្រៃយ៍*

ដោយសារយើងមានឋានៈដែលមិនផ្លាស់ប្តូរ នោះយើងក៏មានការធានាពីព្រះជាម្ចាស់ក្នុងការការពារដ៏អចិន្ត្រៃយ៍ផងដែរ។ ទោះបើថា ក្តីសន្យានៃការការពារដ៏អចិន្ត្រៃយ៍មួយនេះទំនងជាអាចបង្កើតឲ្យមានសំណើចក្អាកក្អាយចេញពីអស់អ្នកដែលដឹងអំពីគ្រីស្ទបរិស័ទដែលពលីជីវិត ឬពីអ្នកជឿដ៏សាមញ្ញៗដែលប្រឈមមុខក្នុងការឈឺចាប់ ឬក៏ការបាត់បង់ក៏ដោយ ក៏ការការពាររបស់ព្រះជាម្ចាស់នៅតែពិត ហើយក៏អាចទុកចិត្តបានដដែល។

តើឲ្យអស់អ្នកដែលអាចដកបទពិសោធន៍នឹងការរងទុក្ខលំបាកដ៏តតឈប់ឈរក្នុងជីវិតនេះអាចទំនងជាជឿការការពារដ៏អចិន្ត្រៃយ៍របស់ព្រះជាម្ចាស់បានដោយរបៀបណាទៅ? យើងអាចរកចម្លើយបានក្នុងការចងចាំថា ជីវិតមួយនេះគឺមិនមែនជាទីបញ្ចប់នៃការមានជីវិតរបស់យើងនោះទេ ហើយវាមិនមែនជាចំណុចដ៏សំខាន់ជាងគេផងដែរ។ ព្រះយេស៊ូវបានមានបន្ទូលថា «កុំឲ្យខ្លាចចំពោះអ្នកដែលសម្លាប់បានតែរូបកាយ តែពុំអាចនឹងសម្លាប់ដល់ព្រលឹងរបស់អ្នកបាននោះឡើយ ស៊ូឲ្យខ្លាចព្រះអង្គវិញជាជាង ដែលទ្រង់អាចនឹងធ្វើ

ឲ្យទាំងព្រលឹង នឹងរូបកាយវិនាសទៅក្នុងនរកផង» (ម៉ាថាយ ១០:២៨)។

ព្រះជាម្ចាស់មានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើការធានាលើឋានៈដ៏អស់កល្បជានិច្ចរបស់យើង ជាជាងលើការធ្វើឲ្យពេលវេលាដ៏មិនអចិន្ត្រៃយ៍របស់យើងមានភាពស្រណុកសុខស្រួលឥឡូវនេះ។ ដោយសារមូលហេតុនេះហើយបានជាទ្រង់ដាក់ការការពារនេះនៅជុំវិញជីវិតយើងខាងឯព្រលឹងវិញ្ញាណ ដើម្បីកុំឲ្យមានអ្វីមួយអាចចូលមកបំផ្លាញឋានៈដ៏នៅអស់កល្បជានិច្ចរបស់យើងជាមួយនឹងព្រះអង្គបាន។ បើនិយាយឲ្យចំទៅ តើឲ្យព្រះជាម្ចាស់ស្រឡាញ់យើងដូចដែលទ្រង់ស្រឡាញ់ព្រះយេស៊ូវបានយ៉ាងដូចម្ដេចទៅ ប្រសិនបើព្រះជាម្ចាស់អនុញ្ញាតឲ្យយើងធ្វើ ឬក៏ដកបទពិសោធន៍នូវអ្វីមួយដែលអាចបណ្ដាលឲ្យយើងធ្លាក់ទៅក្នុងស្ថាននរកយ៉ាងអស់កល្បជានិច្ច? ក្នុងពិភពលោកដែលបានធ្លាក់ក្នុងអំពើបាបមួយនេះ យើងនឹងប្រឈមមុខនឹងទុក្ខលំបាកជាច្រើន (លោកុប្បត្តិ ៣:១៧-១៩) ប៉ុន្តែ ព្រះជាម្ចាស់នឹងមិនអនុញ្ញាតឲ្យមានអ្វីមួយកើតឡើង ដើម្បីបំផ្លាញទំនាក់ទំនងរបស់យើងជាមួយនឹងព្រះអង្គឡើយ (រ៉ូម ៨:៣៥-៣៩)។

យើងទំនងជាមិនអាចដឹងពីមូលហេតុជាក់លាក់ទាក់ទងនឹងការរងទុក្ខណាមួយនោះទេ ទាល់តែព្រះអម្ចាស់ពន្យល់អំពីមូលហេតុទាំងនោះនៅឯស្ថានសួគ៌ ប៉ុន្តែយើងដឹងអំពីគោលបំណងទូទៅរបស់ព្រះអង្គរួចទៅហើយ។ សាវ័ក ប៉ុល បានសរសេរថា «គ្រប់ការទាំងអស់ផ្សំគ្នា សម្រាប់សេចក្ដីល្អដល់ពួកអ្នកដែលស្រឡាញ់ព្រះ» (រ៉ូម ៨:២៨)។ នេះគឺជាក្ដីសន្យាដ៏អស្ចារ្យ៖ ព្រឹត្តិការណ៍នៃចក្រវាលនេះមិនបានកើតឡើងដោយចៃដន្យនោះឡើយ។ ព្រះអង្គ

ធ្វើរាល់គ្រប់អ្វីៗទាំងអស់សម្រាប់ជាសេចក្តីល្អដល់រាស្ត្ររបស់ទ្រង់។ សារ៉ក ប៉ុល បានបន្តដោយពណ៌នាថា តើ «សេចក្តីល្អ» មានន័យយ៉ាងដូចម្តេច? គាត់បានលើកឡើងថា រាល់គ្រប់អ្វីៗផ្តុំគ្នា ដើម្បីធ្វើឲ្យយើងបានក្លាយដូចជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់ «ដើម្បីឲ្យព្រះរាជបុត្រាបានធ្វើជាបងច្បងគេក្នុងពួកបងប្អូនជាច្រើន» (រ៉ូម ៨:២៩)។

ព្រះជាម្ចាស់កំពុងប្រកបមុខរបរជាប្រចាំថ្ងៃក្នុងការពង្រីក និងធ្វើឲ្យគ្រួសាររបស់ព្រះអង្គកាន់តែពេញវ័យ ដើម្បីឲ្យស្ថានសួគ៌កាន់តែមានមនុស្សច្រើនទៀតដែលមានលក្ខណៈដូចជាព្រះយេស៊ូវ។ ដើម្បីរចនាក្នុងយើង (និងបង្ហាញទៅកាន់អ្នកដទៃ) នូវលក្ខណសម្បត្តិ និងក្តីមេត្តាករុណាដូចព្រះគ្រីស្ទ ព្រះជាម្ចាស់របស់យើងអនុញ្ញាតឲ្យយើងដកបទពិសោធន៍ក្នុងការរងទុក្ខលើផែនដីនេះ។ ការរងទុក្ខអស់ទាំងនេះអាចធ្វើឲ្យយើងចេះផ្តាច់ខ្លួនចេញពីការស្រឡាញ់យ៉ាងខ្លាំងនូវអ្វីៗដែលមិននៅអចិន្ត្រៃយ៍ នឹងជួយឲ្យយើងយល់ ហើយរស់នៅសម្រាប់កិត្តិយសដ៏ល្អនៃអាទិភាពដ៏អស់កល្បរបស់ព្រះជាម្ចាស់ (២កូរិនថូស ៤:១៧)។ ទោះជាយ៉ាងណាក្តី ក៏ព្រះអង្គមិនអនុញ្ញាតឲ្យយើងទ្រទ្រង់លើសអ្វីដែលយើងអាចទ្រទ្រង់បាននោះទេ (១កូរិនថូស ១០:១៣) ទ្រង់មិនដែលដកចេញនូវព្រះវត្តមាននៃក្តីស្រឡាញ់របស់ទ្រង់ឡើយ (ហេព្រើរ ១៣:៥) ហើយខណៈពេលដែលការរងទុក្ខពង្រឹងជំនឿរបស់យើង នោះជាទូទៅព្រះអង្គតែងតែប្រទានព្រះពរ ដើម្បីនឹងពង្រឹងដួងចិត្តយើង (បរិទេវ ៣:២៣)។

ព្រះជាម្ចាស់ថ្លឹងថ្លែងទាំងទឹកភ្នែក និងសំណើចដែលចាំបាច់ក្នុងរូបមន្តនៃសេចក្តីល្អដ៏អស់កល្បជានិច្ចរបស់យើង (និងរបស់អ្នកជិតខាងយើង)។ នេះ

ហើយបានជាវាមិនមែនជាសេចក្តីឆោតក្នុងការដែល ដាវីឌ បានសរសេរពីក្នុងគុកនៅពេលយប់មួយនោះទេថា «ខ្ញុំខូចចិត្តណាស់ពេលដែលខ្ញុំគិតអំពីម៉ាក់ប៉ា [ឈឺចាប់]។ ខ្ញុំទៅយំបន្តិចសិនមុនខ្ញុំអធិស្ឋាន ហើយទៅដេក»។ មនុស្សឆ្លាតវាងវៃម្នាក់ទំនងជាសើចចំអកដាក់ការអធិស្ឋានទៅកាន់ព្រះមួយអង្គនេះដែលអនុញ្ញាតឲ្យមានមូលហេតុក្នុងការយំបែបនោះ។ ទោះជាយ៉ាងណាក្តីក៏ទឹកភ្នែករបស់ ដាវីឌ គឺមិនមែនជាការបដិសេធថាព្រះជាម្ចាស់មិនមានព្រះវត្តមានក្នុងជីវិតរបស់គាត់នោះទេ ប៉ុន្តែគឺជាមូលហេតុចំតែម្តងក្នុងការដែលគាត់ត្រូវអធិស្ឋាន។ ដាវីឌ ជឿជាក់ថាព្រះជាម្ចាស់នឹងធ្វើការលើសការបះបោរនិងការឈឺចាប់របស់គាត់ ដើម្បីសម្រេចសេចក្តីដ៏ល្អបាន។ នៅគ្រានោះ ដាវីឌមិនទាន់ស្គាល់សេចក្តីដ៏ល្អរបស់ព្រះជាម្ចាស់សម្រេចនៅឡើយទេ ប៉ុន្តែគាត់នឹងស្គាល់វានៅពេលខាងមុខនេះ ខណៈពេលដែលព្រះជាម្ចាស់បើកសម្តែងពីអំណាចនៃការអធិស្ឋាន។

*អំណាចផ្ទាល់ខ្លួន*

ការធានាទីបីនៃការដែលព្រះជាម្ចាស់យកយើងមកចិញ្ចឹមគឺការមានអំណាចផ្ទាល់ខ្លួន។ ចំណុចដ៏គួរឲ្យអស្ចារ្យលើសជាងសេចក្តីសន្យារបស់ព្រះជាម្ចាស់ថា ទ្រង់នឹងផ្តុំរាល់គ្រប់អ្វីៗសម្រាប់ជាសេចក្តីល្អគឺទាក់ទងនឹងមធ្យោបាយដែលទ្រង់ប្រើប្រាស់។ ឧទាហរណ៍៖ ក្តីសន្យានៃការប្រើប្រាស់រាល់គ្រប់អ្វីៗសម្រាប់ជាប្រយោជន៍ដល់យើងកើតឡើងក្នុងការវែកញែកការអធិស្ឋាន។ ជាដំបូងសាវ័ក ប៉ុល បានទទួលស្គាល់ថា «យើងមិនដឹងជាគួរអធិស្ឋានសូមអ្វីនោះទេ» (ផ្ទុយគ្នាទាំងស្រុងជាមួយនឹងមនុស្សឥឡូវនេះដែលធ្វើពុតថាខ្លួនដឹងយ៉ាង

ច្បាស់)។ បន្ទាប់មកសាវ័ក ប៉ុល បានបន្ថែមដូចតទៅ៖ «តែព្រះវិញ្ញាណទ្រង់ជួយអង្វរជំនួសយើង ដោយដំងូរដែលរកថ្លែងពុំបានវិញ...ដ្បិតព្រះវិញ្ញាណជួយអង្វរជួសពួកបរិសុទ្ធ ឲ្យត្រូវនឹងព្រះហឫទ័យព្រះ» (រ៉ូម ៨:២៦-២៧)។ អស្ចារ្យមែន! ទោះបើយើងមិនដឹងគ្រប់គ្រាន់ក្នុងការទូលឲ្យព្រះជាម្ចាស់ធ្វើនូវអ្វីដែលល្អបំផុតក៏ដោយ ក៏ព្រះវិញ្ញាណបរិសុទ្ធបកប្រែសេចក្តីអធិស្ឋានរបស់យើងឲ្យក្លាយទៅជាការទូលអង្វរដ៏ល្អឥតខ្ចោះសម្រាប់ឲ្យព្រះហឫទ័យរបស់ព្រះជាម្ចាស់បានសម្រេចឡើងបាន។

ខណៈពេលដែលយើងទូលដោយទទូចអង្វរក្នុងបរិបទនៃសេចក្តីប្រាថ្នាដ៏ធំសម្រាប់ឲ្យព្រះហឫទ័យរបស់ព្រះជាម្ចាស់បានសម្រេច (សូមមើលបន្ថែមក្នុងកណ្ឌគម្ពីរ ម៉ាថាយ ៦:១០) នោះព្រះអង្គឆ្លើយតបដោយធ្វើនូវរាល់គ្រប់អ្វីៗផ្គុំគ្នាសម្រាប់សេចក្តីល្អដល់យើង។ ព្រះជាម្ចាស់រចនាពិភពលោកនៅជុំវិញយើងជាថ្មី ដើម្បីឲ្យអ្វីដែលល្អបំផុតខាងព្រលឹងវិញ្ញាណកើតឡើងចំពោះយើង។ តាមរយៈការអធិស្ឋានរបស់យើង យើងបានរួមចំណែកជាមួយនឹងព្រះជាម្ចាស់ក្នុងការបង្កើតនូវធាតុពិតណាថ្មីមួយទៀត។ ដោយសារយើងអធិស្ឋាននោះរាល់គ្រប់អ្វីៗបានផ្លាស់ប្តូរ—មិនមែនដោយសារការអធិស្ឋានរបស់យើងមានអំណាចខ្លាំង ឬក៏ល្អនោះទេ ប៉ុន្តែគឺដោយសារព្រះជាម្ចាស់ដែលយើងបានអធិស្ឋានទៅកាន់ទ្រង់មានអំណាចខ្លាំង ឬក៏ល្អទេតើ។

អ្នកនិពន្ធព្រះគម្ពីរសញ្ញាថ្មីតែងតែលើកឡើងយ៉ាងសាមញ្ញម្តងហើយម្តងទៀតក្នុងដំណឹងល្អថា ព្រះយេស៊ូវគឺជាព្រះអម្ចាស់។ នេះមិនមែនគ្រាន់តែជាវោហារសាស្រ្តប៉ុណ្ណោះទេ ប៉ុន្តែគឺជាការប្រកាសផ្ទាល់ថាអង្គដែលបានបង្កើត

រាល់គ្រប់អ្វីៗទាំងអស់បានយាងមក ដូចដែលព្រះជាម្ចាស់បានសន្យា ដើម្បីរំដោះរាស្ត្ររបស់ទ្រង់តាមរយៈអំណាចព្រះចេស្ដា (ម៉ាកុស ១:១៥; កិច្ចការ ២:៣៦; ១០:៣៦)។ នៅពេលដែលរាល់គ្រប់អ្វីៗបានសម្រេចជាស្រេចទាំងស្រុង នោះអំណាចនេះនឹងអាចកើតមានឡើងយ៉ាងពេញទីបាន ប៉ុន្តែសូម្បីតែឥឡូវនេះក៏វាកំពុងបំផ្លាស់បំប្រែនូវរាល់គ្រប់ធាតុពិតតាមរយៈការអធិស្ឋានរបស់យើងផងដែរ។

គ្រួសាររបស់ខ្ញុំបានរកឃើញថា ក្តីសន្យានៃដំណឹងល្អបែបនេះគឺមិនមែនឥតប្រយោជន៍ទេ (អេសាយ ៦៥:២៤; អេភេសូរ ៣:២០)។ មូលហេតុមួយដែលប្អូនប្រុសខ្ញុំ ដាវីឌ យំសម្រាប់អ្នកម្ដាយ និងលោកឪពុកខ្ញុំគឺដោយសារពួកគាត់បានបែកបាក់គ្នា។ ហើយសម្ពាធរាល់សតវត្សបានជំរុញឲ្យពួកគាត់ឃ្លាតចេញពីគ្នា ហើយធ្វើឲ្យការរងទុក្ខរបស់ប្អូនប្រុសខ្ញុំកាន់តែមានការពិបាកក្នុងការប្រឈមមុខ។ ដូច្នេះ បន្ទាប់ពីគាត់បានទទួលជឿព្រះយេស៊ូវមក ដាវីឌ ក៏ចាប់ផ្ដើមអធិស្ឋានសម្រាប់ឪពុកម្ដាយខ្ញុំដែលកំពុងតែចាស់ទៅៗហើយ—ពួកគាត់បានបែកបាក់គ្នាអស់រយៈពេលប្រមាណជាង ១៥ ឆ្នាំមកហើយ—ឲ្យពួកគាត់បានមករកគ្នាវិញ។ ខ្ញុំមិនមានចិត្តក្លាហានក្នុងការប្រាប់គាត់ថា សេចក្តីអធិស្ឋានរបស់គាត់គឺឥតប្រយោជន៍ទេ។ ប៉ុន្តែ ខ្ញុំជិតនឹងទទួលបានការរម្លឹកអំពីសេចក្តីពិតតាមបែបព្រះ គម្ពីរ ដែលបេះដូងរបស់ខ្ញុំត្រូវការឈោងចាប់យកជាថ្មីម្តងទៀត។

ប្រមាណអាទិត្យមុនកូនស្រីរបស់ខ្ញុំរៀបការ អ្នកម្ដាយរបស់ខ្ញុំបានទូរស័ព្ទមក ហើយបានប្រាប់ថាគាត់ និងលោកឪពុកខ្ញុំរៀបចំគម្រោងមកចូលរួមដែរ។

គាត់បានបន្ថែមទៀតថា «យើងនឹងនៅសណ្ឋាគារដូចគ្នា—ក្នុងបន្ទប់តែមួយ»។ ហើយខណៈពេលដែលខ្ញុំកំពុងតែភ្ញាក់ផ្អើលដោយនៅស្ងៀម គាត់ក៏ថែមទាំងខ្សឹបថា «វាមិនមែនជារឿងមិនសមរម្យទេ។ ចូរចាំថា យើងនៅរៀបការនៅឡើយ»។

ខ្ញុំបានសួរថា «ម៉ាក់! តើរវាងម៉ាក់ និងប៉ារឿងរ៉ាវល្អជាងមុនមែនឬ?»។ គាត់បានតបវិញទាំងទឹកភ្នែកថា «តាមរយៈការដោះស្រាយបញ្ហានៃភាពលំបាករបស់ប្អូនប្រុសឯង ប៉ាកូននឹងម៉ាក់បានរៀនពឹងផ្អែកគ្នាទៅវិញទៅមកជាថ្មីម្តងទៀត»។ បន្ទាប់មក ខ្ញុំក៏យំដែរ—ហើយក៏ស្ញប់ស្ញែងនឹងព្រះអង្គដែលបានផ្គុំនូវរាល់អ្វីៗឲ្យក្លាយទៅជាល្អវិញ និងប្រើប្រាស់អ្វីដែលសាមញ្ញនៅផែនដីនេះ ដើម្បីឲ្យពួកអ្នកប្រាជ្ញអាម៉ាស់ (១កូរិនថូស ១:២៧)។ ខ្ញុំគួរតែបានរំពឹងលើសហ្នឹង ពីព្រះអម្ចាស់របស់ខ្ញុំជាងខ្ញុំបានរំពឹងទៅទៀត។ ប៉ុន្តែ ប្អូនប្រុសខ្ញុំដែលមានព្រំដែនក្នុងការគិតគូរ ត្រូវបានគេកាត់ក្តីដោយសារអំពើឧក្រិដ្ឋ កំពុងតែជាប់ក្នុងគុក បានជឿយ៉ាងសាមញ្ញលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ហើយអធិស្ឋានសូមជំនួយពីព្រះអង្គ ហើយទ្រង់ក៏បានឆ្លើយតបដូចដែលទ្រង់ជ្រាបយ៉ាងល្អប្រសើរ។

ឥឡូវនេះ ពេលដែលអ្នកម្តាយខ្ញុំអាយុ ៧៩ ឆ្នាំ និងឪពុកខ្ញុំអាយុ ៨២ ឆ្នាំទៅសួរសុខទុក្ខប្អូនខ្ញុំនៅក្នុងគុក ពួកគាត់ដើរកាត់ខ្សែលួសដោយកាន់ដៃគ្នា។ ហើយខ្ញុំនិយាយទៅកាន់អស់អ្នកដែលហ៊ានទទួលជឿដូចខ្ញុំ «ដំណឹងល្អគឺជាការពិត។ វាបំផ្លាស់បំប្រែលោកីយ៍នេះ»។ ខ្ញុំនឹងមិនសន្យាថា ព្រះជាម្ចាស់នឹងឆ្លើយតបយ៉ាងចំៗនៅពេលដែលយើងទូលសូម ឬក៏ថាយើងនឹងតែងតែឃើញ

លទ្ធផលនៃការអធិស្ឋានរបស់យើងក្នុងជីវិតនេះនោះទេ ប៉ុន្តែខ្ញុំនឹងសន្យាថា—ដោយសារព្រះបន្ទូលក៏បានធ្វើដូចគ្នា—ព្រះជាម្ចាស់នឹងផ្តុំរាល់គ្រប់អ្វីៗសម្រាប់ជាសេចក្តីល្អចំពោះអស់អ្នកណាដែលស្រឡាញ់ទ្រង់។

*ការលូតលាស់ខាងឯព្រលឹងវិញ្ញាណ*

អំណាចផ្ទាល់ខ្លួនដែលព្រះជាម្ចាស់បានធានាមកកាន់យើងតាមរយៈការទទួលការក្លាយជាកូនចិញ្ចឹមរបស់ទ្រង់មិនមែនគ្រាន់តែសម្រាប់ពិភពលោកនៅខាងក្រៅយើងប៉ុណ្ណោះនោះទេ ប៉ុន្តែក៏សម្រាប់ខាងក្នុងជីវិតរបស់យើងផងដែរ។ អ្នកជឿនឹងមិនអធិស្ឋានសម្រាប់អ្វីមួយណាផ្សេងយ៉ាងអស់ពីចិត្តខ្លាំងជាងឲ្យជីវិតរស់នៅរបស់ពួកគាត់នាំមកនូវសិរីល្អទៅកាន់ព្រះអង្គសង្គ្រោះរបស់ខ្លួនឡើយ។ ទោះជាយ៉ាងណាក្តី ក៏យើងនៅតែទទួលការឡោមព័ទ្ធពីការល្បួង ហើយជារឿយៗដោយសារយើងខ្សោយខាងឯព្រលឹងវិញ្ញាណនោះយើងច្រើនតែចាញ់។ ទាក់ទងនឹងការតយុទ្ធទាំងនេះដំណឹងល្អនាំមកនូវការធានាទីបួនចំពោះបុត្រាបុត្រីរបស់ព្រះជាម្ចាស់៖ ព្រះអង្គប្រទានមកកាន់យើងនូវធនធានពីខាងក្នុងសម្រាប់ការធ្វើសង្គ្រាមជាមួយនឹងអំពើបាប។

ដំណើរការនៃការដែលយើងបានលូតលាស់ក្នុងការមានលក្ខណៈដូចជាព្រះគ្រីស្ទគឺហៅថា «ការញែកជាបរិសុទ្ធ»។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានលើកឡើងនូវចំណុចអនុវត្តជាច្រើនដែលជួយឲ្យយើងពេញវ័យក្នុងដំណើរការនេះបាន។ ទី១ ព្រះគម្ពីរប្រាប់យើងអំពីសេចក្តីរំពឹងរបស់ព្រះជាម្ចាស់។ ទ្រង់មិនធ្វើឲ្យយើងទាយទេ។ ផ្ទុយទៅវិញ ព្រះជាម្ចាស់ប្រទាននូវការណែនាំ ដែលរក្សាយើងទុកឲ្យមានសន្តិភាពខាងឯព្រលឹងវិញ្ញាណ ហើយបំពេញសេចក្តី

ប្រាថ្នារបស់យើងក្នុងការថ្វាយសិរីល្អទៅកាន់ទ្រង់វិញ ខណៈពេលដែលលោកីយ៍នេះគិតថា ក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ប្រៀបដូចជាការបង្ខាំងការជប់លៀង គ្រីស្ទបរិស័ទយល់ឃើញថា តាមពិតទៅ បញ្ញត្តិរបស់ព្រះជាម្ចាស់នាំយើងទៅក្នុងផ្លូវដែលនាំឲ្យទ្រង់សព្វព្រះហឫទ័យយ៉ាងខ្លាំង ហើយនាំយើងឲ្យស្កប់ចិត្តដែរ។

ដើម្បីកុំឲ្យលោកីយ៍នេះបំបោសយើងធ្លាក់ទៅក្នុងការបោកបញ្ឆោតរបស់វាបាន ព្រះជាម្ចាស់ក៏បានប្រាប់ឲ្យយើងរៀនចេញពីព្រះបន្ទូលរបស់ទ្រង់ដែរប្រកបគ្នាជាមួយនឹងព្រះអង្គក្នុងការអធិស្ឋាន ថ្វាយបង្គំជាមួយនឹងរាស្ត្ររបស់ទ្រង់ ហើយសុំប្រឹក្សាពីអស់អ្នកដែលពេញវ័យខាងឯព្រលឹងវិញ្ញាណក្នុងផ្លូវរបស់ទ្រង់។ តាមការប្រើប្រាស់ «យាននៃព្រះគុណ» ទាំងនេះ នោះយើងលូតលាស់ខាងឯការកោតខ្លាចព្រះជាម្ចាស់។ ក្នុងកម្រិតខ្លះៗ យាននៃព្រះគុណទាំងនេះមានឥទ្ធិពលជាសាមញ្ញ គឺដោយសារជាទូទៅតាមធម្មជាតិ យើងឆ្លើយតបតាមបែបដំណើរការដែលកើតឡើងក្នុងបែបធម្មជាតិនៃការសិក្សា និងឥរិយាបថ។ ប្រសិនបើយើងស្រេកទឹក នោះយើងទទួលជំនួយតាមរយៈការផឹកទឹក ហើយបើយើងតយុទ្ធនឹងសេចក្ដីល្បួង នោះការព្រឹក្សាចេញពីព្រះគម្ពីរនឹងជួយយើងគេចចេញពីវាជាមិនខាន។

ប៉ុន្តែ ការញែកជាបរិសុទ្ធរបស់យើងគឺមិនមែនជាដំណើរការបែបធម្មជាតិតែប៉ុណ្ណោះនោះឡើយ។ ព្រះគម្ពីរមានចែងថា សង្គ្រាមខាងឯព្រលឹងវិញ្ញាណរបស់យើងគឺមិនមែនទាស់ប្រឆាំងនឹងសាច់ឈាមនោះទេ ប៉ុន្តែទាស់ប្រឆាំងនឹងសេចក្ដីអាក្រក់ខាងឯវិញ្ញាណ—ទាំងចេញពីខាងក្នុង និងពីខាងក្រៅយើង

(អេភេសូរ ៦:១២)។ការនេះទាមទារការតយុទ្ធខ្លាំងជាងមនុស្សយើងអាចផ្ដល់ឲ្យជាដំណោះស្រាយបានទៅទៀត។ ដូច្នេះ ព្រះអម្ចាស់ក៏ប្រើប្រាស់យាននៃព្រះគុណទាំងនេះ ដើម្បីផ្ដត់ផ្គង់មកកាន់យើងនូវអំណាចព្រះចេស្ដាបែបអធម្មជាតិសម្រាប់ជ័យជម្នះខាងវិញ្ញាណដែលយើងត្រូវការ។

អំណាចព្រះចេស្ដាខាងឯព្រលឹងវិញ្ញាណជ្រាបចូលក្នុងជីវិតរបស់យើងតាមរយៈជំនឿដែលថា យើងគឺជាអ្វីដែលព្រះបន្ទូលរបស់ព្រះជាម្ចាស់លើកឡើង៖ យើងបានកើតជាថ្មីក្នុងព្រះគ្រីស្ទយេស៊ូវ។ មុនមានយើងគឺមានព្រះវត្តមានរបស់ទ្រង់ក្នុងដួងចិត្តរបស់យើង យើងមិនមានលទ្ធភាពក្នុងការមិនប្រព្រឹត្តអំពើបាបឡើយ។ ប៉ុន្តែ ព្រះយេស៊ូវបំផ្លាស់បំប្រែយើង។ ព្រះអង្គប្រទានព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់មកកាន់ដួងចិត្តយើង ដើម្បីរម្លឹកដាស់តឿនយើងនៅពេលដែលយើងប្រព្រឹត្តអំពីអំពើបាប (ឧទាហរណ៍៖ បង្វែរឲ្យយើងពិតជាជឿថាវាខុសមែន) និងដើម្បីធ្វើជាជំនួយក្នុងការតយុទ្ធរបស់យើង។ យើងមិនមែនគ្មានជំនួយទាស់នឹងអារក្សសាតាំងនោះទេ (កូឡុស ១:១៣)។ សាវ័កយ៉ូហាន បានសរសេរថា «ព្រះ [វិញ្ញាណបរិសុទ្ធ] ដែលគង់ក្នុងអ្នករាល់គ្នានោះទ្រង់ធំជាងអា [សាតាំង] នោះដែលនៅក្នុងលោកីយ៍ផង» (១យ៉ូហាន ៤:៤)។ ព្រះវិញ្ញាណដែលប្រោសព្រះយេស៊ូវឲ្យរស់ឡើងវិញពីការសុគតក៏ជាព្រះវិញ្ញាណដែលកំពុងគង់នៅក្នុងពួកយើង និងប្រទានឲ្យនូវអំណាចព្រះចេស្ដាសម្រាប់យកឈ្នះលើអំពើបាបដែរ។

អារក្សសាតាំងនឹងនៅព្យាយាមបញ្ចុះបញ្ចូលយើងថា វាជារឿងធម្មតាទេក្នុងការបរាជ័យ ហើយថាយើងមិនអាចតយុទ្ធនឹងវាបានឡើយ។ ទោះជាយ៉ាង

ណាក្តី ក៏ព្រះបន្ទូលរបស់ព្រះជាម្ចាស់មានលើកឡើងថា យើងអាចតយុទ្ធបាន ពីព្រោះយើងមិនបានរំពឹងលើអំណាចខាងឯសាច់ឈាមតែប៉ុណ្ណោះដូចមុន នោះទេ (រ៉ូម ៨:១១)។ ប្រាកដណាស់! ប្រសិនបើយើងមិនជឿថា យើងអាច ទទួលបានជ័យជម្នះ នោះយើងបានចាញ់សង្គ្រាមរួចទៅហើយ។ នេះឯងជា ជំនឿដ៏សាមញ្ញក្នុងសេចក្តីពិតនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់គឺជាដើមចមនៃ ជ័យជម្នះខាងឯព្រលឹងវិញ្ញាណ។ ការប្រើប្រាស់យាននៃព្រះគុណឲ្យទៀង ទាត់នឹងពង្រឹងជំនឿ ដែលយើងធ្វើឡើងដោយរំពឹងលើអំណាចជាក់ស្តែង របស់យើង។

*សន្តិភាពខាងឯព្រលឹងវិញ្ញាណ*

ព្រះជាម្ចាស់ក៏សព្វព្រះហឫទ័យប្រើប្រាស់យាននៃព្រះគុណ ដើម្បីដាំ យ៉ាងជ្រៅក្នុងយើងនូវការទទួលស្គាល់យ៉ាងជ្រាលជ្រៅថា សូម្បីតែបើយើង មិនមែនមានជ័យជម្នះលើរាល់ការចម្បាំងក៏ដោយ ក៏ព្រះអង្គមិនស្រឡាញ់ យើងតិចជាងមុននោះទេ។ មិត្តភក្តិម្នាក់របស់ខ្ញុំដែលមានប្រាជ្ញាយ៉ាងជ្រាល ជ្រៅបានសរសេរដូចតទៅ «បុគ្គលដែលលូតលាស់ខាងឯព្រលឹងវិញ្ញាណគឺ ជាបុគ្គលដែលដឹងថា ទោះបើខ្លួនគាត់មិនចេះលូតលាស់ក៏ដោយ ក៏មិនមែន មានន័យថា ព្រះជាម្ចាស់ស្រឡាញ់គាត់តិចជាងមុននោះដែរ»។ ស្តាប់ទៅ ចំណុចនេះហាក់បីដូចជាមិនអាចទៅរួចនោះទេ ហើយក៏បញ្ច្រាសគំនិតទៀត ផង។ ប្រសិនបើមនុស្សយើងដឹងថា ការបរាជ័យរបស់គេមិននាំឲ្យព្រះជាម្ចាស់ ដកចេញសេចក្តីស្រឡាញ់របស់ទ្រង់ តើការនោះនឹងនាំឲ្យពួកគេនៅតែបន្ត ប្រព្រឹត្តិអំពើបាបនៅក្នុងខ្លួនទៀតមែនឬ? ប្រាកដណាស់! នឹងមានមនុស្ស

បះបោរ ហើយមិនយល់អារម្មណ៍ដែលពួកគេនឹងកេងប្រវ័ញ្ចផលប្រយោជន៍នៃព្រះគុណ ប៉ុន្តែអស់អ្នកដែលចុះចូលចំពោះព្រះវិញ្ញាណរបស់ព្រះជាម្ចាស់នឹងមិនធ្វើដូច្នោះនោះឡើយ។

មុននឹងយើងអាចយល់អំពីរបៀបនៃសេចក្តីស្រឡាញ់ដែលមិនរាថយរបស់ព្រះជាម្ចាស់បានជំរុញឲ្យយើងញែកជាបរិសុទ្ធបាន ជាដំបូងដាច់ខាត យើងត្រូវតែពិចារណាលើសំណួរគន្លឹះមួយជាមុនសិន៖ «តើអ្វីទៅដែលធ្វើឲ្យអំពើបាបមានអំណាចនៅក្នុងជីវិតរបស់លោកអ្នក?» ចម្លើយគឺ៖ «អំពើបាបមានអំណាចក្នុងជីវិតលោកអ្នក ពីព្រោះលោកអ្នកស្រឡាញ់វា»។ បើអំពើបាបមិនទាក់ទាញលោកអ្នក នោះវានឹងមិនមានអំណាចក្នុងការល្បួងលោកអ្នកឡើយ។ នៅមានសំណួរមួយទៀត៖ «តើមានផ្លូវតែមួយគត់ណាទៅ ដើម្បីបំផ្លាស់នូវក្តីស្រឡាញ់សម្រាប់អំពើបាបចេញបាន?» ចម្លើយគឺ៖ «ត្រូវមានក្តីស្រឡាញ់ខ្លាំងជាងនោះ»។ នៅពេលដែលយើងស្រឡាញ់ព្រះយេស៊ូវខ្លាំងជាងអំពើបាប នោះយើងនឹងចង់ផ្គាប់ព្រះហឫទ័យទ្រង់ខ្លាំងជាងការដែលយើងចង់ធ្វើតាមតែអំពើចិត្តជាមួយនឹងអ្វីដែលមិនត្រឹមត្រូវជាមិនខាន (យ៉ូហាន ១៤:១៥)។ ការស្រឡាញ់អំពើអាក្រក់ធ្វើឲ្យអំពើបាបមានអំណាចលើយើង តែការស្រឡាញ់ព្រះយេស៊ូវនឹងបណ្តេញការស្រឡាញ់អំពើអាក្រក់ចេញពីជីវិតរបស់យើង។

សំណួរចុងក្រោយគឺ៖ «តើអ្វីទៅដែលធ្វើឲ្យលោកអ្នកស្រឡាញ់ព្រះយេស៊ូវ?» ជាថ្មីម្តងទៀត ព្រះគម្ពីរបានឆ្លើយយ៉ាងសាមញ្ញថា៖ «យើងស្រឡាញ់ទ្រង់ ពីព្រោះទ្រង់បានស្រឡាញ់យើងជាមុន» (១យ៉ូហាន ៤:១៩)។ ឥឡូវនេះទើបយើងអាចយល់អំពីមូលហេតុយ៉ាងច្បាស់លាស់ ដែលនេះមិនមែនជាការ

ពិតថា «ប្រសិនបើព្រះជាម្ចាស់ស្រឡាញ់យើង—ទោះបើយើងមានបាប—នោះយើងនឹង "ជប់លៀងឲ្យខ្លាំង" ជាងមុន» នោះទេ។ នៅពេលដែលយើងពិតជាស្រឡាញ់ព្រះអង្គមែន នោះយើងនឹងចង់ធ្វើនូវអ្វីៗ ដើម្បីជាការផ្គាប់ចិត្តដល់ទ្រង់ជាមិនខាន។ ហើយអ្វីដែលធ្វើឲ្យយើងកាន់តែចង់ផ្គាប់ចិត្តព្រះអង្គគឺការស្គាល់ថាក្ដីស្រឡាញ់ដែលមិនចេះប្រែប្រួលរបស់ព្រះអង្គនឹងមិនមានទីបញ្ចប់ឡើយ (បរិទេវ ៣:២២-២៣)។ ការស្រវាស្រទេញនៃព្រះគុណរបស់ទ្រង់ទៅកាន់បុត្រាបុត្រីរបស់ព្រះអង្គគឺជាចំណុចជំរុញនៃអំណាចព្រះចេស្ដា ដើម្បីឲ្យយើងមានភាពបរិសុទ្ធក្នុងចិត្ត (រ៉ូម ១២:១-៣)។

មិនយូរប៉ុន្មានបន្ទាប់ពី ដាវីឌ បានចូលគុក គាត់ក៏ចាប់ផ្ដើមផ្ញើសំបុត្រមកកាន់យើង ដែលគាត់បានសរសេរចម្លងខគម្ពីរយ៉ាងប្រហែស និងពាក្យពេចន៍បទចម្រៀងថ្វាយបង្គំដែលក្រុមអធិស្ឋានរបស់គាត់បានច្រៀង។ ហើយគាត់ក៏បានចុះហត្ថលេខាលើសំបុត្ររបស់គាត់ដែរ «ព្រះប្រទានពរឯង»។ ទោះបើគាត់នៅក្នុងគុកក៏ដោយ—ដោយប្រឈមនឹងសេចក្ដីល្បួង និងការល្បួងលលើសពីអ្វីដែលខ្ញុំអាចដឹងបាន—ក៏គាត់មើលមកខ្លួនឯងថា ជាឧបករណ៍សម្រាប់ជាការប្រកាសសិរីល្អរបស់ព្រះជាម្ចាស់ដែរ។ គាត់ចង់ឲ្យជីវិតគាត់ឆ្លុះបង្ហាញពីព្រះគុណដែលគាត់បានទទួលបទពិសោធន៍លើ។ គ្មាននរណាម្នាក់បង្ខំឲ្យគាត់សរសេរពាក្យពេចន៍ទាំងនេះនោះទេ ហើយក៏គ្មាននរណាអាចបង្ខំបានឡើយ។ ប៉ុន្តែ ក្ដីស្រឡាញ់របស់គាត់សម្រាប់ព្រះយេស៊ូវបានក្លាយជាថាមពលនៃការជំរុញក្នុងជីវិតរបស់គាត់ហើយ ដែលការនេះគឺតែងតែជាការពិតចំពោះអស់អ្នកដែលដឹងអំពីសេចក្ដីស្រឡាញ់ដែលគ្មានលក្ខខណ្ឌរបស់ព្រះគ្រីស្ទ និង

អំពីព្រះគុណដែលគ្មានទីបញ្ចប់។

*មរតកដ៏នៅអស់កល្បជានិច្ច*

ការធានាទី៥សម្រាប់បុត្រាបុត្រីរបស់ព្រះជាម្ចាស់គឺជាមរតករបស់ពួកគេ (អេភេសូរ ១:១៤; ២:៧)។ ព្រះគម្ពីរបានលើកឡើងថា ក្នុងនាមជាបុត្រាបុត្រីដែលព្រះជាម្ចាស់យកមកចិញ្ចឹម យើងគឺជាអ្នកស្នងមរតករួមជាមួយព្រះគ្រីស្ទ (រ៉ូម ៨:១៧)។ ខ្ញុំនឹងគ្រាន់តែលើកឡើងអំពីចំណុចសំខាន់ៗមួយចំនួននៃដំណឹងល្អមួយនេះនៅក្នុងកូនសៀវភៅនេះ។ ចំណុចទី១គឺ៖ ជីវិតដ៏នៅអស់កល្បជានិច្ច ដែលនេះមិនមែនមានន័យថា នឹងមានឆ្នាំដែលគ្មានទីបញ្ចប់នៃការលេងពិននៅលើពពកនោះទេ។ នៅពេលដែលអ្នកជឿស្លាប់ទៅ ភ្លាមៗនោះព្រលឹងរបស់ពួកគាត់នឹងចូលទៅកាន់ព្រះវត្តមានដ៏មានពេញទៅដោយសិរីល្អរបស់ព្រះវរបិតាដែលគង់នៅស្ថានសួគ៌ (១កូរិនថូស ៥:៨; ភីលីព ១:២១-២៤)។ ភ្លាមៗនោះយើងនឹងទទួលបានការទទួលស្គាល់យ៉ាងពេញទី អំណរយ៉ាងពេញលេញ និងសន្តិភាពយ៉ាងគង់វង្ស ប៉ុន្តែនេះមិនមែនជាសាច់រឿងទាំងមូលនៅឡើយទេ (លូកា ២៣:៤៣)។ ថ្ងៃមួយ ព្រះគ្រីស្ទទ្រង់នឹងយាងមកវិញ ហើយទ្រង់នឹងរចនាជាថ្មីនៅអ្វីដែលទ្រង់បានបង្កើតជាដំបូងយ៉ាងល្អ (អេសាយ ៦៥:១៧-១៩; រ៉ូម ៨:២១-២៣)។ រាល់ប្រយោជន៍ដែលមនុស្សយើងគួរមានអំណរជាមួយនៅគ្រាដំបូងក្នុងសួន អេដែន នឹងត្រូវបានស្ដារឡើងវិញ—ប្រភពដែលមានពេញទៅដោយការប្រទានឲ្យនូវអ្វីៗដែលជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់ និងមិនមានវត្តមាននៃការរងទុក្ខទៀតឡើយ (វិវរណៈ ២១:៤)។

របស់សព្វសារពើនឹងត្រូវបានស្តារឡើងវិញ ហើយយើងក៏នឹងត្រូវបានរចនាជាថ្មីឡើងវិញក្នុងព្រលឹងវិញ្ញាណ រូបកាយ និងចិត្តគំនិតផងដែរ (១កូរិនថូស ១៥:៥២-៥៤)។ ដាវីឌ ដែលជាប្អូនប្រុសខ្ញុំដែលកំពុងជាប់គុក គាត់នឹងមិនគ្រាន់តែស្គាល់ការអត់ទោសយ៉ាងពេញទីរបស់ព្រះជាម្ចាស់ប៉ុណ្ណោះនៅអនាគតនោះទេ ប៉ុន្តែរូបកាយរបស់គាត់នឹងត្រូវបានបរិសុទ្ធឡើងវិញ ហើយចិត្តគំនិតរបស់គាត់នឹងបានប្រសើរឡើង និងពេញលេញជាលើកដំបូងទៀតផង។ ប្អូនប្រុសរបស់ខ្ញុំនឹងមានសិរីរុងរឿងលើសជាងពួកទេវតាទៅទៀត (១យ៉ូហាន ៣:២-៣)។ គាត់នឹងដើរដោយមានសេរីភាពក្នុងការបង្កើតជាថ្មីដោយងើបក្បាលឡើង ភ្នែកពេញដោយពន្លឺ និងដួងចិត្តដែលមានពេញដោយអំណរក្នុងអ្វីៗដែលស្រស់ស្អាតនៅជុំវិញគាត់។ សមាជិកគ្រួសារខ្ញុំអស់អ្នកដែលបានចាកចេញទៅបាត់ហើយ—និងអស់អ្នកដែលនឹងចូលស្ថានសួគ៌—នឹងមានការជួបជុំជាមួយនឹងគាត់ និងជាមួយអស់អ្នកដែលស្រឡាញ់ព្រះយេស៊ូវដែរ (១ថែស្សាឡូនីច ៤:១៤-១៨)។ យើងនៅមានពិធីជប់លៀងលើតុនៃព្រះអម្ចាស់យើង និងមានអំណរក្នុងសេចក្តីសប្បុរសរបស់ទ្រង់ ព្រមទាំងមានអំណរដ៏អស់កល្បជានិច្ចក្នុងពិភពដែលត្រូវបានបង្កើតឡើងយ៉ាងល្អឥតខ្ចោះតាមរយៈព្រះគុណរបស់ព្រះអម្ចាស់យើង។ អង្គដែលបានយាងមកសង្គ្រោះមនុស្សមានបាប ទ្រង់នឹងប្រទានឲ្យសេចក្តីសង្គ្រោះក្នុងលក្ខណៈដ៏ធំដែលថា វាក៏ជាការស្តារពិភពលោកទាំងមូលឡើងវិញនេះដែរ មានរួមទាំងជីវិតយើងទាំងមូលហើយក៏នឹងនៅអស់កល្បជានិច្ចទៀតផង (វិវរណៈ ២១:១)។

# អស់អ្នកដែលព្រះជាម្ចាស់ធ្វើឲ្យល្អឥតខ្ចោះ ទ្រង់ប្រើប្រាស់

## *គោលបំណងបុគ្គលនីមួយៗ*

ក្តីស្រឡាញ់ដ៏មានតម្លៃរបស់ព្រះគ្រីស្ទចំពោះរាស្ត្ររបស់ទ្រង់ និងផែនដីរបស់ពួកគេ—ដែលបានឃើញយ៉ាងច្បាស់លាស់តាមរយៈការដែលព្រះអង្គសង្គ្រោះទាំងពីរនោះ—មានការជះឥទ្ធិពលយ៉ាងខ្លាំងក្លាលើអស់អ្នកដែលស្រឡាញ់ទ្រង់។ ដោយសារយើងស្រឡាញ់ទ្រង់ នោះយើងក៏នឹងស្រឡាញ់អ្វីៗ និងបុគ្គលណាដែលទ្រង់ស្រឡាញ់ដែរ។ មិនយូរប៉ុន្មានបន្ទាប់ពីគាត់បានប្តេជ្ញាចិត្តចំពោះព្រះគ្រីស្ទ ប្អូនប្រុសរបស់ខ្ញុំ ដាវីឌ—ដែលពីមុនឆ្លើយទាំងក្នុងពាក្យពេចន៍ និងឥរិយាបថ—បានសរសេរថា «ញ៉ុមស្រឡាញ់ព្រះយេស៊ូវណាស់ [ហើយឥឡូវនេះ] ញ៉ុមមិនអាចទទួលបានទេ ពេលមនុស្សប្រើប្រាស់ឈ្មោះព្រះអង្គមិនគួរសម។ ញ៉ុមចង់ឲ្យគេដឹងថាទ្រង់ល្អណាស់។» ពេលដែលព្រះយេស៊ូវគង់ក្នុងដួងចិត្តរបស់យើង នោះដួងចិត្តរបស់ទ្រង់នឹងក្លាយជារបស់យើងដែរ (រ៉ូម ៦:៤-១១)។

បុគ្គលណាដែលស្រឡាញ់ព្រះអង្គនឹងចង់ផ្គាប់ព្រះហឫទ័យទ្រង់ដោយស្រឡាញ់អស់អ្នកដែលទ្រង់ស្រឡាញ់ដែរ។ យើងពេញចិត្តក្នុងការធ្វើជារាជទូតរបស់ព្រះអង្គទៅកាន់ពួកអ្នកបាត់បង់ ធ្វើជាព្រះហស្តទ្រង់ទៅកាន់អស់អ្នកដែលត្រូវការ ធ្វើជាសំឡេងទ្រង់សម្រាប់អស់អ្នកដែលគេជិះជាន់ និងជាអ្នកត្រួតត្រាលើអ្វីដែលទ្រង់បានបង្កើតទុកជាការផ្គត់ផ្គង់សម្រាប់មនុស្សទាំងអស់

គ្នា។ យើងមានអំណរត្រង់ថា គ្រួសារនៅក្នុងព្រះអង្គមានលើសជាងព្រំដែននៃជាតិសាសន៍ តំបន់ ឋានៈ និងប្រពៃណី ហើយយើងពេញចិត្តក្នុងការស្រឡាញ់តាមកាលៈទេសៈដែលអាចធ្វើបាន។ ហើយខណៈពេលដែលយើងបង្ហាញពីក្ដីស្រឡាញ់របស់ព្រះគ្រីស្ទក្នុងយើង នោះយើងដែលធ្លាប់មានតម្រូវការខ្លួនឯងនឹងនៅជាចុងបញ្ចប់នៃការរកឃើញទស្សនៈមួយនៃសេចក្ដីសង្គ្រោះរបស់ព្រះគ្រីស្ទ៖ គោលបំណងរបស់ព្រះជាម្ចាស់។

ព្រះអង្គបានរំដោះយើងចេញពីជីវិតដែលគ្មានន័យ ក៏ដូចជាជីវិតដែលមានពេញទៅដោយអំពើបាបផងដែរ (១ពេត្រុស ១:១៨)។ ព្រះយេស៊ូវធ្វើឲ្យអ្នកបាក់បែកមានប្រយោជន៍ឡើងវិញ។ ព្រះយេស៊ូវមិនទាន់បញ្ចប់ដាច់ស្រេចជាមួយនឹងបុរស ដែលការបរាជ័យរបស់គាត់បាននាំឲ្យគាត់ជាប់គុកជាមួយនឹងប្អូនប្រុសរបស់ខ្ញុំនៅឡើយនោះទេ។ ខណៈពេលដែលបុរសម្នាក់នោះបានចែកចាយជំនឿរបស់គាត់ជាមួយនឹងប្អូនប្រុសរបស់ខ្ញុំ—ដែលជាបុរសពីជាតិសាសន៍មួយផ្សេងទៀត—បុគ្គលទាំងពីរនាក់ក៏បានស្គាល់សេចក្ដីស្រឡាញ់របស់ព្រះគ្រីស្ទ ហើយក៏បានក្លាយជាបងប្អូនខាងឯព្រលឹងវិញ្ញាណយ៉ាងអស់កល្បជានិច្ច។

ម្ដងហើយម្ដងទៀត ប្អូនប្រុសរបស់ខ្ញុំដែលមានការខ្វះខាតខាងឯការលូតលាស់ក្នុងខួរក្បាលក៏បានទទួលជំនួយនៅក្នុងគុកតាមរយៈបុរសនានាដែលមានជាតិសាសន៍ខុសៗគ្នា និងមានប្រវត្តិខុសៗគ្នាដែលក្នុងសហគមន៍ធម្មតានឹងមានការបែកបាក់គ្នាជាប្រាកដ ហើយខណៈពេលដែល ដាវីឌ បន្តរៀនអំពីសេចក្ដីស្រឡាញ់ដែលធំជាងការរើសអើងរបស់គាត់ គាត់ក៏បានក្លាយ

ជាឧបករណ៍មួយនៃសេចក្ដីស្រឡាញ់របស់ព្រះគ្រីស្ទផងដែរ។ ការទុកចិត្តដ៏សាមញ្ញ និងការមានទំនាក់ទំនងជាមួយនឹងអស់អ្នកមិនមានលក្ខណៈដូចគាត់ បាននាំមកនៅក្នុងជញ្ជាំងគុកនោះនូវសិរីរុងរឿងនៃភាតរភាពក្នុងស្ថានសួគ៌។

*គោលបំណងរួម*

ក្នុងនាមជាបុគ្គលនីមួយៗ យើងរួមចំណែកក្នុងគោលបំណងនៃការបំផ្លាស់បំប្រែរបស់ព្រះគ្រីស្ទ ប៉ុន្តែក៏មានការរួបរួមក្នុងនាមជាអ្នកជួបជុំគ្នាផងដែរ។ តាមរយៈក្រុមជំនុំ យើងប្រកាសអំពីដំណឹងល្អរបស់ព្រះគ្រីស្ទក្នុងពាក្យពេចន៍នឹងទង្វើ ដើម្បីឲ្យការត្រួតត្រារបស់ព្រះអង្គជ្រាបចូលពីចិត្តមួយទៅចិត្តមួយ និងកាត់ចូលរាល់ជាតិសាសន៍ (កូឡូស ១:២២-២:៤)។ មូលដ្ឋាននៃនគររបស់ព្រះអង្គគឺជាដំណើររឿងដែលបទគម្ពីរបានបើកសម្ដែងឲ្យឃើញចាប់តាំងពីពីរទៅបីទំព័រមុនដំបូងម្ល៉េះ។ ព្រះជាម្ចាស់របស់យើងនឹងមិនទុកចោលនៅអ្វីៗដែលទ្រង់បានបង្កើតឲ្យឈឺចាប់ក្នុងការបាក់បែករបស់វានោះទេ។ ទោះបើការក្បត់បាននាំឲ្យមានការបែកបាក់ក្នុងលោកីយ៍នេះ និងអស់អ្នកដែលរស់នៅលើផែនដីនេះក៏ដោយ ក៏ព្រះជាម្ចាស់មិនដែលបោះបង់ចោលដែរ។ ព្រះអង្គសង្គ្រោះមនុស្សលោក ដើម្បីឲ្យពួកគេស្គាល់ ហើយនឹងចែកចាយពីព្រះគុណរបស់ទ្រង់។ សរុបសេចក្តីទៅ សេចក្តីសង្គ្រោះដែលទ្រង់នាំមកគឺសម្រាប់ទាំងនិងតាមរយៈមនុស្សមានបាប។ ក្នុងក្រុមជំនុំ យើងជួបជុំគ្នា ដើម្បីសរសើរតម្កើងទ្រង់ទាក់ទងនឹងសេចក្តីល្អនេះ លើកទឹកចិត្តគ្នាទៅវិញទៅមកឲ្យរស់នៅសម្រាប់ព្រះអង្គ ហើយនឹងដើម្បីជួយឲ្យអ្នកដទៃយល់ និងដកពិសោធន៍ពីក្តីស្រឡាញ់ដែលមានការបំផ្លាស់បំប្រែរបស់ទ្រង់។

តាំងពីដើមមក ការលាតត្រដាងដំណើររឿងនៃសេចក្តីសង្គ្រោះគឺសម្រាប់យើង បូកបញ្ចូលទាំងយើងហើយក៏បានក្រសោបយើងចូលទៅក្នុងការឱបក្រសោបមួយដ៏ធំផ្សេងទៀតដែរ។ យើងមានគោលបំណងលើសពីខ្លួនឯងទៅទៀត ហើយក្នុងការបំពេញគោលបំណងនោះជាមួយនឹងអ្នកដទៃ នោះយើងអបអរសាទរអត្តសញ្ញាណរួមគ្នារបស់យើងក្នុងរូបកាយរបស់ព្រះគ្រីស្ទ។ រួមគ្នា ព្រះអង្គប្រទានមកកាន់យើងនូវការបំពេញ និងការរួមចំណែកក្នុងការពង្រីកនគររបស់ទ្រង់ ដើម្បីបំផ្លាស់បំប្រែរាល់គ្រប់អ្វីៗសម្រាប់សិរីល្អរបស់ទ្រង់ (អេភេសូរ ១:២១)។ ខណៈពេលដែលយើងរស់នៅក្នុងសង្គមដែលលើកទឹកចិត្តគ្នា ណែនាំគ្នា ពង្រឹងគ្នា និងអត់ទោសឲ្យគ្នាទៅវិញទៅមក នោះយើងនឹងក្លាយជាអំបិល និងពន្លឺដែលបំផ្លាស់បំប្រែលោកីយ៍ដែលយើងកំពុងតែរស់នៅក្នុងជាមិនខាន (ម៉ាថាយ ៥:១៣-១៦; អេភេសូរ ៣:១០-២១)។

*គោលបំណងនៃការសង្គ្រោះ*

ទាក់ទងនឹងអភ័យឯកសិទ្ធិដ៏ធំនៃការរួមចំណែកក្នុងពន្ធកិច្ចនៃការបំផ្លាស់បំប្រែរបស់ព្រះគ្រីស្ទ យើងក៏បានទទួលសេចក្តីសង្គ្រោះ ហើយទាក់ទងនឹងគោលបំណងដ៏ធំមួយនេះ នោះយើងថ្វាយព្រះកិត្តិយសដល់ស្តេចរបស់យើង និងឆ្លុះបង្ហាញអំពីព្រះគុណរបស់ព្រះអង្គក្នុងរាល់ចំណុចនៃជីវិតរបស់យើង—ពោលគឺទំនាក់ទំនងរបស់យើង ការអរសប្បាយដែលយើងធ្វើ និងការថ្វាយបង្គំរបស់យើង។ យើងមិនបង្ខាំងចំណុចជីវិតណាមួយរបស់យើងពីការឆ្លុះបង្ហាញអំពីសិរីល្អរបស់ទ្រង់ឡើយ ខណៈពេលដែលទ្រង់ពង្រីកការត្រួតត្រារបស់ព្រះអង្គលើរាល់ចំណុចនៃជីវិត។

ចំណុចខុសគ្នានៃភាពបរិសុទ្ធ និងអសាសនានិយមគឺមិនត្រូវយកមកប្រើប្រាស់ ដើម្បីវែកញែកនូវអ្វីដែលព្រះគ្រីស្ទយកព្រះហឫទ័យទុកដាក់ក្នុងចំណុចនៃជីវិតរស់នៅទេ។ ទ្រង់គឺជាព្រះអម្ចាស់ដែលបានយាងមក ហើយក៏នឹងយាងមកជាថ្មីម្តងទៀត ដើម្បីពង្រីកការត្រួតត្រាដ៏មានពេញទៅដោយព្រះគុណរបស់ទ្រង់លើគ្រប់អ្វីៗទាំងអស់។ ព្រះអង្គសង្គ្រោះយើងដើម្បីដាក់ការធានាអះអាងរបស់ទ្រង់លើយើង។ ខណៈពេលដែលយើងមានការស្តុបចិត្តយ៉ាងធំមហិមាក្នុងការថ្វាយនូវរាល់គ្រប់ចំណុចនៃគ្រប់ជីវិតរស់នៅរបស់យើងទៅកាន់ព្រះអង្គ នោះទ្រង់នឹងសព្វព្រះហឫទ័យក្នុងការប្រើប្រាស់យើងសម្រាប់គោលបំណងដ៏នៅអស់កល្បជានិច្ច និងដើម្បីសង្គ្រោះលោកីយ៍នេះតាមរយៈការខិតខំព្យាយាមរបស់យើងបែបជាបុគ្គលនីមួយៗ និងបែបជាការរួបរួមគ្នាដែរ។

នៅពេលដែលអ្នកនិពន្ធដំណឹងល្អប្រកាសអំពីដំណឹងល្អរបស់ព្រះគ្រីស្ទជាទូទៅគឺត្រូវបានធ្វើឡើងដោយប្រកាសថា ព្រះអម្ចាស់នៃរាល់គ្រប់អ្វីៗបានយាងមកដល់ហើយ។ គ្មានអំណរណាអាចនឹងកើតមានឡើងស្របគ្នាជាមួយនឹងការប្រកាសបែបនេះបានឡើយ ប្រសិនបើវាមានការកត់សម្គាល់លើតែជាមួយនឹងការចាប់ផ្តើមការត្រួតត្រាដោយកាន់អំណាចផ្តាច់ការទេ។ ទោះជាយ៉ាងណាក្តី ប្រសិនបើស្តេចបានយាងមកសង្គ្រោះមនុស្សមានបាប ហើយប្រសិនបើសេចក្តីសង្គ្រោះរបស់ពួកគេមានរួមទាំងការស្តារដួងចិត្តជាថ្មី ការប្រទានអំណាចក្នុងការរស់នៅ និងពិភពលោកដែលទទួលបានការបំផ្លាស់បំប្រែនោះគោលបំណងរបស់ទ្រង់ និងរបស់ពួកគេគឺពិតជាដំណឹងល្អមែន។ ដំណឹងនេះ

គឺពិតជាល្អមែន ដ្បិតសូម្បីតែពួកទេវតាក៏ទន្ទឹងរង់ចាំមើលដែរ ហើយយើងដែលស្រឡាញ់ព្រះអង្គ ដែលទ្រង់បានប្រទានដំណឹងល្អនេះ ក៏យកចិត្តទុកដាក់ក្នុងការប្រកាសវាដែរ (១ពេត្រុស ១:១០-១២)។ ទោះបើថា យើងបានស្គាល់ការជាប់គុកខាងឯរូបកាយ គំនិត ទង្វើ ពិរុទ្ធភាព ទំនាក់ទំនង ឬក៏ក្នុងកាលៈទេសៈមួយណាក៏ដោយ ក៏ព្រះយេស៊ូវគ្រីស្ទបានយាងមក ដើម្បីសង្គ្រោះយើងយ៉ាងអស់កល្បជានិច្ចចេញពីអ្វីៗទាំងអស់នោះដែរ។ នេះគឺដំណឹងដ៏ល្អអស្ចារ្យមែន—ហើយវាពិតជាដំណឹងល្អ!